

*សេចក្តីផ្តើម*

## **តើសេចក្តីស្រឡាញ់ដ៏ពិតជាអ្វី?**

មនុស្សម្នាក់ៗ កំពុងតែស្វែងរកសេចក្តីស្រឡាញ់។ ប៉ុន្តែ តើសេចក្តីស្រឡាញ់ដ៏ពិត មានរូបរាង្គដូចម្តេចខ្លះ? តើធ្វើដូចម្តេចឲ្យយើងដឹងថា យើងបានរកឃើញសេចក្តីស្រឡាញ់ដ៏ពិតហើយ? អ្នកខ្លះយល់ថា "ការស្រឡាញ់" ជាអារម្មណ៍ម្យ៉ាងដែលមិនអាចពិពណ៌នាបាន ដែលយើងបានធ្លាក់ចូល ឬបានបណ្តាលចិត្តយើង។ តែព្រះគម្ពីរបរិសុទ្ធ ដែលផ្ទុកទៅដោយប្រាជ្ញាសម្រាប់គ្រប់សម័យកាល បានផ្តល់ឲ្យយើងនូវការបកស្រាយដែលមានន័យជាងនេះ និងស្ថិតស្ថេរយូរអង្វែងជាងផង។

នៅក្នុងទំព័រដែលនឹងមានជាបន្តបន្ទាប់នេះ លោកប៊ីល ក្រោដឺរ(Bill Crowder) ដែលជាគ្រូគង្វាល និងគ្រូបង្រៀនព្រះគម្ពីរ សូមនាំអារម្មណ៍យើង ឲ្យស្វែងយល់អំពីបទគម្ពីរ ១កូរិនថូស ១៣:៤-៨ ជាថ្មីឡើងវិញ។ លោកបប់ លីន(Bob Lind) ដែលជាអ្នកនិពន្ធបានពិពណ៌នា គេពិបាកនឹងយល់ អំពីសត្វមេអំបៅដ៏ស្រស់ស្អាតនៃសេចក្តីស្រឡាញ់។ ប៉ុន្តែ ពេលដែលគេបានយល់ច្បាស់ អំពីអត្ថន័យនៃបទគម្ពីរ ១កូរិនថូស ១៣:៤-៨ ហើយ នោះគេអាចនិយាយថា សេចក្តីស្រឡាញ់មិនពិបាកយល់ដូចនោះទេ។



Mart DeHaan

# មាតិកា

*ទី១*
**អ្វីដែលលោកិយត្រូវការ សព្វថ្ងៃនេះ………………………..៣**
*ទី២*
**ទីក្រុងដែលត្រូវការសេចក្ដីស្រឡាញ់……………………..៧**
*ទី៣*
**ភស្តុតាងនៃសេចក្ដីស្រឡាញ់ដ៏ពិត…………………………១១**
*ទី៤*
**សេចក្ដីស្រឡាញ់មិនដែលផុតឡើយ……………………...២៩**
*ទី៥*
**តើខ្ញុំអាចទៅរកសេចក្ដីស្រឡាញ់ នៅឯណា?……………...៣១**

អ្នកគ្រប់គ្រងផ្នែកកែសម្រួលអត្ថបទ : J. R. Hudberg
រចនាក្របដោយ: Terry Bidgood
រចនាផ្នែកខាងក្នុងដោយ : Steve Gier
រចនាផ្នែកខាងក្នុងដោយ: Terry Bidgood. Via Stock.Xchng: ( ទំព័រ 3 ) Shannon Pifko; ( ទំព័រ .7 ) Cristi Modoran; ( ទំព័រ .11 ) Andrejs Pidjass; ( ទំព័រ .29 ) Gavin Terpstra; ( ទំព័រ .31 ) Leszek Nowak
ប្រែសម្រួលជាភាសាខ្មែរ ដោយ : លោក ឯក សត្យា
បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤
ដោយការអនុញ្ញាត និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល។
រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2015 ODB Ministries ( website: www.odb.org )
ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@rbc.org, Tell: 087 233 907, website: http://khmer-odb.org, FB page : https://www.facebook.com/RBCCambodia )



*ទី១*

## អ្វីដែលលោកិយត្រូវការ សព្វថ្ងៃនេះ

កាលពីទសវត្សរ៍ឆ្នាំ១៩៦០ អ្នកស្រីជែកឃី ដឺសាណុន(Jackie DeShan-non) បានច្រៀងថា "អ្វីដែលលោកិយត្រូវការនៅពេលនេះ គឺសេចក្ដីស្រឡាញ់ សេចក្ដីស្រឡាញ់ដ៏ផ្អែមល្ហែម" ហើយមនុស្សជាច្រើន ក្នុងសម័យនោះ ក៏បានច្រៀងបទនេះជាមួយនឹងគាត់ផងដែរ។ ចម្រៀងមួយបទនេះ បានបកស្រាយថា លោកិយមិនត្រូវការភ្នំខ្ពស់ៗបន្ថែមទៀតសម្រាប់ឡើង ហើយក៏មិនត្រូវការទន្លេជាច្រើនទៀតសម្រាប់ឆ្លងដែរ។ អ្វីដែលយើងត្រូវការគឺសេចក្ដីស្រឡាញ់ "គឺមិនមែនសម្រាប់តែអ្នកខ្លះទេ តែសម្រាប់មនុស្សគ្រប់គ្នា"។

អត្ថន័យនៃបទចម្រៀងដ៏ពេញនិយមមួយនេះ បានបញ្ចេញសម្លេងដែលយើងម្នាក់ៗសុទ្ធតែអាចស្ដាប់យល់ច្បាស់។ អ្នកដែលបានរៀបការហើយ បានទិញផ្កាកុលាប និងស្ករគ្រាប់ឲ្យប្ដីប្រពន្ធរបស់ខ្លួន ដើម្បីបង្ហាញសេចក្ដីស្រឡាញ់។ ពេលដែលសហគមន៍ណាមួយរងគ្រោះ ដោយសារគ្រោះធម្មជាតិ គេក៏បានរៃអង្គាសប្រាក់ សម្រាប់ជួយជនរងគ្រោះ។ យើងអបអរចំពោះអំពើល្អ ដែលបុគ្គលណាម្នាក់បានធ្វើក្នុងសង្គម ដូចជាលោករូសស៊ែល ផ្លេសង់(Russell Plaisance) ដែលមានអាយុ៧៥ឆ្នាំ ដែលបានព្យាយាមជួយគ្រួសារមួយ ដោយរៀបរាប់អំពីទុក្ខវេទនារបស់គ្រួសារនេះ ក្នុងកាសែតប្រចាំតំបន់របស់គាត់។ លោករូសស៊ែលក៏បានយកលុយ អាហារ និងរបស់លេងសម្រាប់ក្មេងៗ ទៅឲ្យគ្រួសារមួយដែលកំពុងស្នាក់នៅក្នុងបន្ទប់ជួលមួយកន្លែង។ តែគួរឲ្យស្ដាយណាស់ ពីរបីថ្ងៃក្រោយមក អំពើសប្បុរសរបស់លោករូសស៊ែលត្រូវបានតបស្នងវិញ ដោយការអាក្រក់ ពេលដែលបុរសជាឪពុករបស់គ្រួសារនោះ បានយកកូនកាំបិត មកភ្ជង់គាត់ ប្លន់យកកាបូបលុយ និង

ឡានរបស់គាត់។ បទពិសោធន៍របស់លោករូសស៊ែល អាចជួយឲ្យយើងយល់កាន់តែច្បាស់ អំពីមូលហេតុ ដែលលោកិយកំពុងតែត្រូវការសេចក្តីស្រឡាញ់យ៉ាងខ្លាំង។ បើសិនជាសេចក្តីស្រឡាញ់ តែងតែទទួលការតបស្នង ដោយសេចក្តីស្រឡាញ់មកវិញ នោះយើងមិនខ្វះសេចក្តីស្រឡាញ់ទេ។ ប៉ុន្តែ គេមិនតែងតែទទួលបាននូវការតបស្នងដោយសេចក្តីស្រឡាញ់ជានិច្ចឡើយ។ ហើយជួនកាល ពេលដែលយើងទទួលការតបស្នងដោយសេចក្តីស្រឡាញ់ហើយ យើងបែរជាប្រើសេចក្តីស្រឡាញ់នោះ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ។ មនុស្សយើងអាចមានការយល់ឃើញខុសៗគ្នា អំពីសេចក្តីស្រឡាញ់។ សូម្បីតែនៅក្នុងការសន្ទនាធម្មតា យើងប្រើពាក្យស្រឡាញ់ ក្នុងន័យផ្សេងគ្នា។ ឧទាហរណ៍ ខ្ញុំអាចនិយាយថា

"ខ្ញុំស្រឡាញ់កីឡាបាល់ទាត់"។

"ខ្ញុំស្រឡាញ់កំព្យូទ័ររបស់ខ្ញុំ"។

"ខ្ញុំស្រឡាញ់ភរិយា និងកូនរបស់ខ្ញុំ"។

"ខ្ញុំស្រឡាញ់ការងាររបស់ខ្ញុំ"។



ពេលដែលពាក្យមួយមាត់ មានន័យច្រើនដូចនេះ យើងប្រហែលជាមិនដឹង អំពីអត្ថន័យពិតនៃពាក្យនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបានបកស្រាយយ៉ាងច្បាស់ អំពីអត្ថន័យនៃសេចក្តីស្រឡាញ់។ មានពេលមួយ សាវ័កប៉ុលបានសរសេរសំបុត្រទៅកាន់ពួកជំនុំដែលកំពុងរងទុក្ខ ដោយសារសេចក្តីកំហឹង និងការប៉ះទង្គិចគ្នាថា

"ទោះបើខ្ញុំចេះនិយាយ ជាភាសារបស់មនុស្សជាតិទាំងប៉ុន្មាន និងភាសារបស់ពួកទេវតាផង តែគ្មានសេចក្តីស្រឡាញ់ នោះខ្ញុំបានត្រឡប់ដូចជាលង្ហិនដែលឮខ្ទរ ឬដូចជាឈឹង ដែលឮទ្រហឹងប៉ុណ្ណោះ បើខ្ញុំចេះអធិប្បាយ ហើយស្គាល់អស់ទាំងសេចក្តីអាថ៌កំបាំង និងគ្រប់ទាំងចំណេះវិជ្ជា ហើយបើខ្ញុំមានគ្រប់ទាំងសេចក្តីជំនឿល្មមនឹងឲ្យភ្នំរើចេញបាន តែគ្មានសេចក្តីស្រឡាញ់ នោះខ្ញុំមិនជាអ្វីទេ បើខ្ញុំចែកអស់ទាំងទ្រព្យសម្បត្តិខ្ញុំជាអាហារដល់គេ ហើយបើខ្ញុំប្រគល់រូបកាយខ្ញុំទៅឲ្យគេដុត តែគ្មានសេចក្តីស្រឡាញ់ នោះគ្មានប្រយោជន៍ដល់ខ្ញុំសោះ"(១ កូរិនថូស ១៣:១-៣)។

សាវ័កប៉ុលបានសរសេរពាក្យពេចន៍ទាំងអស់នេះ ទៅកាន់មនុស្ស ដែលយល់អំពីសារៈសំខាន់នៃការប្តេជ្ញាចិត្ត និងការលះបង់ផ្ទាល់ខ្លួន។ ពួកជំនុំនៅទីក្រុងកូរិនថូស យល់អំពីតម្លៃនៃសេចក្តីជំនឿ ចំណេះដឹង អំណោយទានខាងវិញ្ញាណ អ្នកដឹក

**បទពិសោធន៍របស់លោករូសសែល អាចជួយឲ្យយើងយល់កាន់តែច្បាស់អំពីមូលហេតុ ដែលលោកិយកំពុងតែត្រូវការសេចក្តីស្រឡាញ់យ៉ាងខ្លាំង។**

នាំដែលរឹងមាំ និងព្រះបន្ទូលលើកទឹកចិត្ត។ ប៉ុន្តែ ពេលដែលពួកគេព្យាយាមស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ពួកគេក៏បានភ្លេចគោលដៅ នៃសេចក្តីជំនឿ និងចំណេះដឹងរបស់ខ្លួន។ ពួកគេបានសិក្សាព្រះគម្ពីរ តែពួកគេភ្លេចថា ខ្លួនបានមើលរំលងបំណងព្រះទ័យព្រះ ដែលព្រះអង្គបានបង្ហាញក្នុងព្រះបន្ទូល។ ពួកគេចង់បានការបំពេញបន្ថែម តែបានភ្លេចថា អ្វីដែលខ្លួនត្រូវការខ្លាំងបំផុតគឺសេចក្តីស្រឡាញ់។



*ទី២*

## ទីក្រុងដែលត្រូវការសេចក្ដីស្រឡាញ់

មានការពិពណ៌នាដ៏ល្អបំផុតជាច្រើន អំពីសេចក្ដីស្រឡាញ់ ដែលក្នុងនោះមានការពិពណ៌នាមួយ ដែលនិយាយទាក់ទងនឹងទីក្រុងកូរិនថូស។ ប៉ុន្តែតើហេតុអ្វីបានជាការពិពណ៌នានេះ ជាប់ទាក់ទងនឹងទីក្រុងមួយនេះ ដែលមានសីលធម៌ធ្លាក់ចុះ និងខ្វះសេចក្ដីស្រឡាញ់ ដោយគេឮល្បីថា ប្រជាជននៅទីនោះ មានភាពអាត្មានិយម នៅក្នុងទំនាក់ទំនង។ ជារៀងរាល់ថ្ងៃ ពួកគេបានបំផ្លាញជីវិតខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ បើយើងសិក្សាឲ្យបានស៊ីជម្រៅ យើងនឹងបានដឹងថា ទីក្រុងកូរិនថូស ពិតជាសក្ដិសមនឹងឲ្យគេលើកមកនិយាយជាឧទាហរណ៍ ព្រោះពួកជំនុំនៅក្រុងកូរិនថូស ជាអ្នកដែលត្រូវការគោលការណ៍ នៃសេចក្ដីស្រឡាញ់ដ៏ពិត ដើម្បីកែប្រែជីវិតរបស់ខ្លួន។

បើធៀបនឹងស្ថានភាពសង្គមបច្ចុប្បន្ន គ្រីស្ទបរិស័ទនៅក្រុងកូរិនថូស មានបញ្ហាជាច្រើនដែលត្រូវជម្នះ។ សាសនាជាមូលដ្ឋាននៅទីក្រុងកូរិនថូស គឺមានការថ្វាយបង្គំព្រះអ័ប្រូឌាយ ដែលជាព្រះនៃសេចក្ដីស្រឡាញ់របស់សាសន៍ក្រិក ហើយគេបានឲ្យស្ត្រីរកស៊ីផ្លូវភេទ១ពាន់នាក់ ធ្វើការជាសង្ឃក្នុងព្រះវិហាររបស់ព្រះនោះ។ ទ្រព្យសម្បត្តិក៏ជាបញ្ហាសម្រាប់គ្រីស្ទបរិស័ទនៅក្រុងកូរិនថូសផងដែរ។ ដោយសារទីក្រុងនេះមានទីតាំងនៅលើតំបន់អ៊ីសម៉ូស ដែលបានតភ្ជាប់តំបន់ខាងជើង និងខាងត្បូងនេះនៃនគរក្រិក ហើយបានផ្ដល់នូវភាពសម្បូរសប្បាយផ្នែកពាណិជ្ជកម្ម ដែលជាហេតុបណ្ដាលឲ្យសីលធម៌នៅទីនោះ មានការធ្លាក់ចុះផងដែរ។ ការរួមផ្សំដ៏គ្រោះថ្នាក់នៃសម្ភារៈនិយម និងសាសនាដែលផ្ដោតទៅលើផ្លូវភេទ បានបង្កើតឲ្យមានវប្បធម៌ ដែលផ្អែកទៅលើការត្រេកត្រអាលផ្ទាល់ខ្លួន។

ហេតុនេះហើយ បានជាបញ្ហានៅក្នុងពួកជំនុំនៅក្រុងកូរិនថូស បានចាប់ផ្ដើមផ្ទុះបញ្ចាំង អំពីស្ថានភាពនៃបរិស្ថានសង្គមនៅសម័យនោះ។ សាវ័កប៉ុលក៏បានផ្ដល់នូវដំណោះស្រាយចំពោះបញ្ហាផ្សេងៗ ក្នុងសំបុត្រទី១ ដែលគាត់បានសរសេរផ្ញើទៅកាន់ពួកជំនុំដែលកំពុងមានការពិបាកនេះ។ បញ្ហាទាំងនោះមានដូចជា :

- ការបែកបាក់ ក្នុងគ្រួសារនៃព្រះ (ជំពូក ១-៣)
- សេចក្ដីអំណួត និងភាពក្រអឺតក្រទមខាងវិញ្ញាណ (ជំពូក ៤)
- អសីលធម៌ផ្លូវភេទ (ជំពូក ៥)
- ការប្ដឹងផ្ដល់គ្នា រវាងគ្រីស្ទបរិស័ទ (ជំពូក ៦)
- ទំនាក់ទំនងប្ដីប្រពន្ធដែលមានបញ្ហា (ជំពូក ៧)
- ការប្រើសេរីភាពខាងវិញ្ញាណក្នុងផ្លូវខុស (ជំពូក ៨-១០)
- កំហុសក្នុងការប្រើអំណោយទានខាងវិញ្ញាណ (ជំពូក ១២,១៤)
- ការមិនយកចិត្តទុកដាក់ចំពោះមូលដ្ឋានគ្រឹះនៃគោលលទ្ធិ (ជំពូក ១៥)



អ្នកអានសំបុត្ររបស់សាវ័កប៉ុល ចាំបាច់ត្រូវដឹងថា ការដើរតាមព្រះគ្រីស្ទ មិនមែនគ្រាន់តែជាការដេញតាមចំណេះដឹង ប្រាជ្ញា និងអំណាចប៉ុណ្ណោះឡើយ។ ទោះពួកគេពូកែជជែកវែកញែក ចេះប្រើគោលលទ្ធិត្រឹមត្រូវ ចេះបង្ហាញចេញនូវក្ដីជំនឿ និងចេះដាក់ដង្វាយ ដោយការលះបង់យ៉ាងណាក៏ដោយ ក៏អ្នកដទៃនៅតែចេញឆ្ងាយពីពួកគេ ព្រោះពួកគេត្រូវស្វែងយល់ឡើងវិញ អំពីអត្ថន័យដ៏ពិតនៃសេចក្ដីស្រឡាញ់។ ត្រង់ចំណុចនេះ សាវ័កប៉ុលបានបកស្រាយ ក្នុងបទគម្ពីរ ១កូរិនថូស ១៣:១-៣ អំពីការអ្វីខ្លះ ដែលនឹងកើតឡើង ពេលដែលសកម្មភាព ជាពិសេសទង្វើល្អរបស់យើង មិនបានធ្វើឡើង ដោយសេចក្ដីស្រឡាញ់។

*ពួកអ្នកក្រុងកូរិនថូស មានការល្បីឈ្មោះខាងភាពអសីធម៌ខ្លាំងណាស់ បានជាគេតែងតែប្រដូច ប្រជាជននៅនគរក្រិក ដែលមានភាពអសីលធម៌ខ្លាំង និងការប្រមិកជ្រុល ទៅនឹងពួកអ្នកក្រុងកូរិនថូស។*

សេចក្តីបង្រៀន ដែលពួកជំនុំក្រុងកូរិនថូសត្រូវការ មានសារៈសំខាន់ចំពោះយើងរាល់គ្នា។ យើងអាចមានការយល់ដឹងច្រើនសណ្ធឹកអំពីព្រះ តើយើងបានយល់ពីបំណងព្រះទ័យព្រះអង្គទេ? បើយើងមិនបានរស់នៅតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធដែលគង់ក្នុងចិត្តយើងទេ នោះយើងប្រហែលជាមិនបានយកចិត្តទុកដាក់ចំពោះអ្នកដទៃឲ្យបានគ្រប់គ្រាន់ឡើយ។ យើងងាយនឹងមើលឃើញកំហុសរបស់អ្នកដទៃ ដោយមិនបានមើលឃើញកំហុសខ្លួនឯង។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីបង្រៀនក្នុងបទគម្ពីរកូរិនថូស ខ្សែទី១ មិនបានថ្កោលទោស ឬសើចចម្អកឲ្យយើងឡើយ តែបទគម្ពីរនេះបានផ្តល់នូវពន្លឺ នៅពេលដែលយើងកំពុងវង្វេង

> ទោះពួកគេពូកែជជែកវែកញែក ចេះប្រើគោលលទ្ធិត្រឹមត្រូវ ចេះបង្ហាញចេញនូវក្តីជំនឿ និងចេះដាក់ដង្វាយ ដោយការលះបង់យ៉ាងណាក៏ដោយ ក៏អ្នកដទៃនៅតែចេញឆ្ងាយពីពួកគេ ព្រោះពួកគេត្រូវស្វែងយល់ឡើងវិញ អំពីអត្ថន័យដ៏ពិតនៃសេចក្តីស្រឡាញ់។

ផ្លូវ។ បទគម្ពីរនេះជួយឲ្យយើងដឹងខ្លួនថា យើងមិនត្រូវបំផ្លាញខ្លួនឯង ដោយសារកំហុសដែលយើងមាន ក្នុងទំនាក់ទំនង ឬដោយសារអាកប្បកិរិយាឆ្គាំឆ្គងរបស់យើងឡើយ។ យើងក៏មិនត្រូវបង្អាប់ព្រះនាមព្រះអង្គ ដោយសារការគិតប្រយោជន៍ផ្ទាល់ខ្លួនដែរ។

អ្នកដទៃមិនសូវខ្វល់ថា យើងចេះព្រះបន្ទូលព្រះច្រើនប៉ុណ្ណាទេ ព្រោះគេឲ្យតម្លៃទៅលើការប្រព្រឹត្តរបស់យើងជាង។ ពួកគេក៏មិនងាយនឹងគិតថា យើងមានជំនឿខ្លាំងទេ ដរាបណា ពួកគេមិនបានឃើញថា យើងខ្វល់អំពីពួកគេ ដូចយើងខ្វល់អំពីខ្លួនឯងទេនោះ។ បើសិនជាគ្មានសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ បណ្តាលចិត្តយើងទេ នោះការផ្សាយដំណឹងល្អរបស់យើង អាចប្រែជាមានលក្ខណៈជំនុំជម្រះ, ការប្រកាន់យកភាពបរិសុទ្ធផ្នែកគោលលទ្ធិ ក៏អាចប្រែជាភាពកំពុត ដូចពួកផារិស៊ី, ការប្តេជ្ញាចិត្តផ្ទាល់ខ្លួន ក៏អាចប្រែជាអំណួត ដែលលើកដំកើងភាពបរិសុទ្ធខ្លួនឯង ហើយការថ្វាយបង្គំអាចក្លាយជាការធ្វើបង្គ្រប់កិច្ចជាទម្លាប់ ដោយគ្មានការពិចារណា។

ព្រះមិនគ្រាន់តែបានត្រាសហៅយើង ឲ្យឡើងទៅកាន់ទីខ្ពស់ប៉ុណ្ណោះទេ។ ព្រះអង្គថែមទាំងបានប្រទាននូវការផ្លាស់ប្រែ ពីខាងក្នុងមកក្រៅ។ ព្រះអង្គសព្វព្រះទ័យនឹងលើកយើងឡើង ឲ្យបានខ្ពស់ជាងជីវិតដែលដើរតាមនិស្ស័យសាច់ឈាម ហើយធ្វើការក្នុងជីវិតយើង ដោយធ្វើការអ្វីដែលយើងមិនអាចធ្វើដោយខ្លួនឯងបាន។

*ពួកផារិស៊ីស្ថិតក្នុងចំណោមក្រុមសាសនាទាំងបីរបស់សាសន៍យូដា ក្នុងអំឡុងពេលព្រះយេស៊ូវបំពេញព្រះរាជកិច្ចក្នុងលោកិយនេះ។ គេឮល្បីថា ពួកគេជាអ្នកកាន់តាមក្រឹត្យវិន័យសញ្ញាចាស់យ៉ាងតឹងរឹង និងមានការប្តេជ្ញាចិត្តខ្លាំង ចំពោះការសម្អាតខ្លួនជាបរិសុទ្ធតាមពិធីបុណ្យ។*



*ទី៣*

## **គន្លឹះនៃសេចក្តីស្រឡាញ់ដ៏ពិត**

នៅសហរដ្ឋអាមេរិក កាលពីសម័យមុន ក្រុមចម្រៀងប៊ីតធលបានតែងបទចម្រៀងថ្មីមួយបទ ហើយបាននាំមនុស្សជំនាន់នោះច្រៀងថា "អ្វីដែលអ្នកត្រូវការ គឺសេចក្តីស្រឡាញ់"។ ជាច្រើនឆ្នាំក្រោយមក ក្រុមចម្រៀងប៊ីតធល ក៏បានមានការជួបជុំគ្នាឡើងវិញ ជាមួយនឹងអ្នកគាំទ្ររបស់ខ្លួន ក្នុងការប្រគុំតន្ត្រីជាសាធារណៈ ដែលនៅពេលនោះ ពួកគេក៏បានច្រៀងជាថ្មីម្តងទៀត អំពីសេចក្តីស្រឡាញ់។ ប៉ុន្តែ ទំនុកចម្រៀងរបស់បទ "ក្តីស្រឡាញ់ពិត" ដែលលោក ចន លែននិន(John Lennon) បាននិពន្ធ បានបង្ហាញនូវភាពសោកសៅ។ ក្នុងបទចម្រៀងនេះ គាត់បានពិពណ៌នាអំពីសេចក្តីស្រឡាញ់ដ៏ពិត ដែលជាគោលដៅនៃជីវិតរបស់គាត់ ហើយនៅចុងបញ្ចប់នៃបទចម្រៀងនេះ គាត់បានរៀបរាប់យ៉ាងសោកសៅថា ទីបញ្ចប់គាត់ "ត្រូវរស់នៅម្នាក់ឯង"។

ទំនុកច្រៀងដែលលោកលេននិនបាននិពន្ធនេះ បានបង្ហាញអំពីបទពិសោធន៍ដែលមិនមែនមានតែមនុស្សជំនាន់គាត់ប៉ុណ្ណោះទេ ដែលបានជួបប្រទះ តែមនុស្សនៅសម័យយើងក៏មានបញ្ហានេះផងដែរ។ យើងស្វែងរកសេចក្តីស្រឡាញ់។ យើងគិតថា យើងបានរកឃើញសេចក្តីស្រឡាញ់ហើយ តែពេលដែលអារម្មណ៍ដ៏រីករាយបានរលាយអស់ហើយ យើងក៏បានដឹងថា នេះគ្រាន់តែជាការភ័ន្តច្រឡំប៉ុណ្ណោះ។

ដូចនេះ តើសេចក្តីស្រឡាញ់ជាអ្វី ហើយហេតុអ្វីបានជាគេហាក់ដូចជាពិបាកយល់ពីអត្ថន័យរបស់វាម្ល៉េះ? នៅសម័យសាវ័កប៉ុលរស់នៅ គេប្រើភាសាក្រិកយ៉ាងទូលំទូលាយ។ បើសិនជាយើងបានរស់នៅសម័យនោះ យើងនឹងកាន់តែងាយយល់

ច្បាស់អំពីអត្ថន័យនៃ "សេចក្តីស្រឡាញ់" តាមភាសាក្រិក។



ក្នុងភាសាក្រិក គេប្រើពាក្យ *អេរ៉ូស (eros)* ដើម្បីរៀបរាប់អំពីសេចក្តីស្រឡាញ់បែបរ៉ូមែនទិក។ ពាក្យ*ស្តូច (Storge)* ពិពណ៌នាអំពីសេចក្តីស្រឡាញ់ដ៏ខ្លាំង ដែលការពារ ធ្វើឲ្យមានសុវត្ថិភាព។ រីឯពាក្យ *ភីលេអូ (Phileo)* វិញ គឺតំណាងឲ្យការស្រឡាញ់គ្នាជាបងប្អូន ជាគ្រួសារ ឬជាមិត្តភក្តិ។ ហើយពាក្យ*អាហ្កាពេ (Agape* ដែលគេច្រើនតែប្រើ ដើម្បីនិយាយអំពីសេចក្តីស្រឡាញ់របស់ព្រះ) រៀបរាប់អំពីសេចក្តីស្រឡាញ់ដ៏ខ្លាំង និងបរិសុទ្ធបំផុត។

សាវ័កប៉ុលបានជ្រើសរើសពាក្យ *អាហ្កាពេ* ដើម្បីរៀបរាប់អំពីសេចក្តីស្រឡាញ់ក្នុងបទគម្ពីរ ១កូរិនថូស ១៣ ដើម្បីឲ្យយើងដឹងថា អាហ្កាពេ ជាសេចក្តីស្រឡាញ់ដ៏ខ្ពស់បំផុត ដែលមកពីព្រះ ដែលមានអត្ថន័យដ៏ពេញលេញ និងស្ថិតស្ថេរ។ សាវ័កប៉ុលបានប្រើពាក្យ *អាហ្កាពេ* ដើម្បីរៀបរាប់នៅក្នុងបទគម្ពីរ អំពីសេចក្តីស្រឡាញ់តាមទស្សនៈរបស់ព្រះអាទិករនៃយើង យ៉ាងដូចនេះថា :

> "ឯសេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្តីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស មិនដែលអរសប្បាយចំពោះសេចក្តីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្តីស្មោះត្រង់វិញ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់ (១កូរិនថូស ១៣:៤-៧)។

ពេលដែលយើងពិចារណាអំពីធាតុផ្សំផ្សេងៗ នៃសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់ក្នុងបទគម្ពីរនេះ យើងអាចយល់កាន់តែច្បាស់ អំពីមូលហេតុដែល *អាហ្កាពេ* ជាសេចក្តីស្រឡាញ់ដ៏ពិត ជាសេចក្តីស្រឡាញ់ដែលយើងរាល់គ្នាត្រូវការ និងចង់បាន។

*គួរបញ្ជាក់ថា ព្រះគម្ពីរសញ្ញាថ្មីបានប្រើតែពាក្យ អាហ្កាពេ និងភីលេអូ ប៉ុណ្ណោះ។*

## លក្ខណៈនៃសេចក្ដីស្រឡាញ់ (ដែលតែងតែអត់ធ្មត់) ជួយឲ្យមនុស្សម្នាក់អាចធ្វើអ្វី ដែលអ្នកដទៃថា ខ្លួនមិនអាចធ្វើបាន។

**សេចក្ដីស្រឡាញ់ "តែងតែអត់ធ្មត់"**

សេចក្ដីស្រឡាញ់តែងតែអត់ធ្មត់ គឺ"អត់ធ្មត់បានយូរ" និងមានការទប់អារម្មណ៍ខ្លួនឯង ពេលដែលមានអ្វីធ្វើឲ្យខឹង ឬឈឺចាប់ ដោយមិនប្រញាប់សងសឹក ឬដាក់ទោសគេភ្លាមៗ ឬអាចមានន័យម្យ៉ាងទៀតថា សេចក្ដីស្រឡាញ់ "គឺយឺតនឹងខឹង"។

សេចក្ដីស្រឡាញ់ដ៏ពិតមិនសងសឹក ឬស្វែងរកឱកាសធ្វើការអាក្រក់ទៅលើគេវិញ ដើម្បីឲ្យរួចគ្នានោះឡើយ។ សេចក្ដីស្រឡាញ់មិនឱបក្រសោបយកភាពល្វីងជូរចត់ឡើយ តែទ្រាំទ្រដោយចិត្តអត់ធ្មត់។ សេចក្ដីស្រឡាញ់ទទួលស្គាល់ការឈឺចាប់ក្នុងចិត្ត ហើយដោះស្រាយបញ្ហានៃការឈឺចាប់នោះ ដោយមិនមានការសងសឹកតបទៅវិញ។ លក្ខណៈនៃសេចក្ដីស្រឡាញ់(ដែលអត់ទ្រាំយូរ) ជួយយើង ឲ្យធ្វើនូវការអ្វីដែលអ្នកដទៃនិយាយថា ខ្លួនមិនអាចធ្វើបាន។

ខ្ញុំសូមលើកឡើង អំពីទីបន្ទាល់របស់អ្នកស្រីយ៉ូអាន(Joan)។ ស្វាមីរបស់នាងបានប្រព្រឹត្តអំពីសាហាយស្មន់ អស់រយៈពេលយ៉ាងយូរ ហើយទីបំផុត ក៏បានបោះបង់គ្រួសារចោល។ ទំនាក់ទំនងប្ដីប្រពន្ធរបស់ពួកគេ ក៏បានបញ្ចប់ ដោយការលែងលះគ្នា។ តែទោះអ្នកស្រីយ៉ូអានមានការឈឺចាប់យ៉ាងក៏ដោយ ក៏គាត់នៅតែនឹកចាំអំពីមូលហេតុដែលគាត់ស្រឡាញ់ស្វាមីរបស់គាត់។

បន្ទាប់ពីគាត់មានទុក្ខសោក និងបានកសាងជីវិតឡើងវិញតែម្នាក់ឯង អស់រយៈពេលជាច្រើនខែក្រោយមក គាត់ក៏បានទទួលដំណឹងថា លោកឆាល(Charles) ដែលជាអតីតស្វាមីរបស់គាត់ បានជួបគ្រោះថ្នាក់ បណ្ដាលឲ្យមានរបួស នៅកន្លែងធ្វើការ ហើយកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ពេលនោះ ព្រះក៏បានប្រើទុក្ខវេទនា ដែលកើតឡើងពីគ្រោះថ្នាក់នោះ ដើម្បីធ្វើឲ្យបុរសម្នាក់នេះ ដែលបានវង្វេងចេញពីគ្រួសារ មានការគិតពិចារណាឡើងវិញ។

ថ្ងៃមួយ លោកឆាល ក៏បានទាក់ទងអ្នកស្រីយ៉ូអាន ហើយបានសួរគាត់ថា តើទំនាក់ទំនងប្ដីប្រពន្ធរបស់យើង ដែលមានការបែកបាក់ នៅមានសង្ឃឹមថា នឹងមានការផ្សះផ្សាឡើងវិញដែរឬទេ? នេះមិនមែនជាសំណួរដែលងាយស្រួលឆ្លើយទេ!

ព្រោះវាអាចជាការបើកទ្វារ ឲ្យការឈឺចាប់ និងទុក្ខសោកចូលមកក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ នៅពេលក្រោយទៀត។ សម្រាប់ស្ត្រីផ្សេងទៀត ដែលជួបរឿងដ៏ឈឺចាប់ដូចអ្នកស្រីយ៉ូអាន ពួកគេប្រហែលជាបដិសេធមិនព្រមផ្សះផ្សាឡើងវិញទេ។ ប៉ុន្តែ ទោះបីជាអ្នកស្រីយ៉ូអាន មានការខ្វល់ខ្វាយក៏ដោយ ក៏គាត់នៅតែព្រមទៅទទួលការប្រឹក្សាផ្លូវចិត្តតាមព្រះគម្ពីរ ជាមួយលោកឆាល អស់ជាច្រើនខែ។ បន្ទាប់ពីអ្នកស្រីយ៉ូអានបានស្ម័គ្រចិត្ត ដោះស្រាយបញ្ហា និងការបាត់បង់ដ៏ឈឺចាប់បំផុតដែលស្ត្រីអាចជួបប្រទះ គាត់ក៏បានរួមរស់ជាមួយលោកឆាលជាប្តីប្រពន្ធឡើងវិញ។

អ្នកស្រីយ៉ូអានមិនព្រមបណ្តោយឲ្យខ្លួនឯងបន្តរស់នៅ ក្នុងភាពល្ងីងល្ងើរចត់ទៀតឡើយ តែការនេះមិនមានន័យថា គាត់អាចបំភ្លេចអតីតកាល បានយ៉ាងងាយ ឬដោយគ្មានការឈឺចាប់នោះឡើយ។ ប៉ុន្តែ សេចក្តីស្រឡាញ់ដ៏ពិត មិនបណ្តោយឲ្យខ្លួនឯងមានចិត្តល្ងីងល្ងើរចត់ទេ។ សេចក្តីស្រឡាញ់ "តែងតែអត់ធ្មត់ ទោះយូរប៉ុណ្ណាក៏ដោយ"។

*សេចក្តីស្រឡាញ់ដែល "**អត់ធ្មត់**" មិនតម្រូវឲ្យអ្នកដែលទទួលរងការឈឺចាប់ បន្តស្ថិតនៅក្នុងស្ថានភាព ដែលមានគ្រោះថ្នាក់ ឬត្រឡប់មករកស្ថានភាពដែលគ្រោះថ្នាក់នោះទៀតឡើយ។ សេចក្តីស្រឡាញ់ដែលពិត តម្រូវឲ្យសកម្មភាពយើងកើតចេញពីចិត្តគំនិតដែលត្រឹមត្រូវ។*

## សេចក្តីស្រឡាញ់ដ៏ពិត "គឺសប្បុរស"

តាមប្រសាសន៍របស់លោក អេ ធី រ៉ូបឺតសិន(A. T. Robertson)ពាក្យជាភាសាក្រិកដែលប្រែមកថា "សប្បុរស" ក៏អាចមានន័យថា "មានប្រយោជន៍ ឬចិត្តល្អ"។ គោលបំណងនៃសេចក្តីស្រឡាញ់ដ៏ពិត គឺជាការស្វែងរកសុខុមាលភាព ឲ្យមនុស្សជាទីស្រឡាញ់របស់យើង ដូចនេះ សេចក្តីស្រឡាញ់ដ៏ពិតមិនគ្រាន់តែអត់ធ្មត់ប៉ុណ្ណោះទេ តែថែមទាំងមានចិត្តល្អផងដែរ។

ភាពសប្បុរសមិនមានចិត្តកាច ហើយងាយនឹងលើកទឹកចិត្តអ្នកដទៃ ឲ្យធ្វើការល្អ។ គឺដូចដែលព្រះគម្ពីរសុភាសិត បានចែងថា "ពាក្យតបឆ្លើយដោយស្រទន់ នោះរមែងរំងាប់សេចក្តីក្រោធទៅ"(១៥:១) ដូចនេះ សេចក្តីស្រឡាញ់ដែលមានការអនុ

*សាវ័កប៉ុលបានប្រើឧទាហរណ៍**វិជ្ជមាន** និង**អវិជ្ជមាន** ដើម្បីបង្ហាញឲ្យបានច្បាស់អំពីលក្ខណៈ និងតួនាទីនៃសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ។*

វត្តជាក់ស្តែង និងមានប្រយោជន៍ នាំឲ្យអ្នកជាទីស្រឡាញ់របស់ខ្លួន ធ្វើការអ្វីដែលល្អបំផុត។

ការមានចិត្តសុភាព និង"ពេញដោយព្រះគុណ" ជាចរិយាសម្បត្តិ ដែលមានលក្ខណៈដូចព្រះគ្រីស្ទ(យ៉ូហាន ១:១៤)។ គឺដូចដែលព្រះយេស៊ូវ បានពិពណ៌នាអំពីព្រះអង្គទ្រង់ ដល់អ្នកដែលកំពុងត្រូវការជំនួយថា "អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង"(ម៉ាថាយ ១១:២៨-២៩)។

នេះជាការពិពណ៌នារបស់អង្គបុគ្គលដែលខ្លាំងបំផុត នឹងមានសេចក្តីស្រឡាញ់ច្រើនលើសគេ ដែលលោកិយបានស្គាល់ ដែលព្រះអង្គខ្លាំងល្មមនឹងបង្កើតចក្រវាល ហើយមានប្រាជ្ញាល្មមនឹងតតាំងនឹងភាពមានពុត និងភាពអាត្មានិយមរបស់មនុស្សដែលមានអំណាចបំផុត នៅសម័យព្រះអង្គ។ តែព្រះអង្គបានតតាំង ដោយសេចក្តីពិត និងពេញជាព្រះគុណ។

ព្រះយេស៊ូវបានរំឭកយើងថា សេចក្តីស្រឡាញ់តម្រូវឲ្យមានសេចក្តីពិត នោះសេចក្តីពិតដែលបង្ហាញចេញមក ដោយគ្មានភាពសប្បុរស មិនមែនជាក្តីស្រឡាញ់ទេ។ ព្រះអង្គបានរំឭកយើងថា ខណៈពេលដែលសេចក្តីស្រឡាញ់ទាមទាភាពអត់ធ្មត់ នោះភាពអត់ធ្មត់ ដែលគ្មានចិត្តសប្បុរស មិនមែនជាសេចក្តីស្រឡាញ់ទេ។

## សេចក្តីស្រឡាញ់ដ៏ពិត "មិនច្រណែនឈ្នានីស"

សាវ័កប៉ុលបានបន្តរៀបរាប់ អំពីអត្ថន័យនៃសេចក្តីស្រឡាញ់ ដោយមានប្រសាសន៍ថា សេចក្តីស្រឡាញ់ដ៏ពិតមិនច្រណែន នឹងព្រះពរ ជោគជ័យ ឬសេចក្តីសុខរបស់អ្នកដទៃឡើយ។ សេចក្តីស្រឡាញ់មិននិយាយថា "បើខ្ញុំយករបស់ដែលខ្ញុំស្រឡាញ់មិនបានទេ ខ្ញុំក៏មិនចង់ឲ្យអ្នកមានរបស់នោះដែរ"។ ផ្ទុយទៅវិញ សេចក្តីស្រឡាញ់និយាយថា "ខ្ញុំអាចអរសប្បាយជាមួយនឹងអ្នក ទោះបីជាខ្ញុំមិនដែលបានទទួលជោគជ័យ ការទទួលស្គាល់ ឬសេចក្តីសុខ ដូចអ្នកក៏ដោយ។ កាលណាខ្ញុំចង់ឲ្យខ្លួនឯង

ទទួលបានបន្ថែមទៀត នោះខ្ញុំចង់ឲ្យអ្នកទទួលបានបន្ថែមទៀតផងដែរ"។



លក្ខណៈនៃសេចក្តីស្រឡាញ់ ដែល"គ្មានការច្រណែនឈ្នានីស" អាចជាលក្ខណៈនៃសេចក្តីស្រឡាញ់ ដែលយើងបានជួបប្រទះញឹកញាប់បំផុត។ តើមានពេលប៉ុន្មានដងហើយ ដែលយើងបានឃើញអ្នកដទៃមានភាពសម្បូរសប្បាយ នៅពេលដែលយើងកំពុងតែមានការខ្វះខាត? សូម្បីតែពួកសិស្សរបស់ព្រះយេស៊ូវ ក៏បានប្រកែកគ្នា អំពីអ្នកដែលត្រូវមានតំណែងធំជាងគេ ក្នុងចំណោមពួកគេផងដែរ។

ព្រះគម្ពីរមិនបានចែងថា យើងនឹងគ្មានការខកចិត្ត ពេលបាត់បង់ការងារ ឬគ្មានការឈឺចាប់ នៅក្នុងទំនាក់ទំនងនោះឡើយ។ សាវ័កប៉ុលមិនបានប្រាប់យើងថា យើងនឹងមិនមានអារម្មណ៍ឈឺចាប់ ឬពិបាកចិត្ត ពេលដែលយើងមានសេចក្តីស្រឡាញ់ឡើយ។ តែគាត់ពិតជាបាននិយាយថា បើសិនជាយើងមានសេចក្តីស្រឡាញ់ដ៏ពិត នោះយើងនឹងមិនមានចិត្តច្រណែនឈ្នានីសទេ។ យើងមិនត្រូវប្រើការឈឺចាប់ជាលេស ដើម្បីច្រណែននឹងអ្នកដទៃដែលបានរបស់ល្អជាងយើងទេ។

តើយើងអាចស្រឡាញ់អ្នកដទៃ ដោយចិត្តដែលល្អដូចនេះ ដោយរបៀបណា? គឺដោយជំនួយពីព្រះវិញ្ញាណនៃព្រះគ្រីស្ទ។ អាថ៌កំបាំង ដើម្បីឲ្យយើងមានចិត្តល្អ ពេលមានការខកចិត្ត គឺយើងត្រូវមានទំនុកចិត្តដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះដែលផ្គត់ផ្គង់យើង ដែលព្រះអង្គក៏ជាអ្នកគង្វាល និងឪពុករបស់យើងផងដែរ។ ការខកចិត្តកើតមានក្នុងការរស់នៅ ជាធម្មតា។ កាលៈទេសៈដែលមានភាពអយុត្តិធម៌ នឹងល្បងលជំនឿ និងក្តីស្រឡាញ់របស់យើង។ តែដរាបណា យើងចេះទុកចិត្តព្រះ នោះយើងនៅតែអាចបង្ហាញក្តីស្រឡាញ់ចំពោះអ្នកដទៃ ទោះមានការខកចិត្តក៏ដោយ។

## សេចក្តីស្រឡាញ់ដ៏ពិត "មិនអួតខ្លួន"

សៀវភៅដែលបង្រៀនយើងឲ្យជួយខ្លួនឯង តែងតែប្រាប់យើងថា ដើម្បីឲ្យបានជោគ

*__សេចក្តីអំណួត__ ជាអំពើបាបដំបូងគេ ដែលសាតាំងបានប្រព្រឹត្ត ពេលដែលវាប្រកាសថា "អញនឹងឡើងទៅផុតទីខ្ពស់នៃពពក អញនឹងលើកខ្លួនឲ្យបានដូចជាព្រះដ៏ខ្ពស់បំផុត"(អេសាយ ១៤:១៤)។*

ជ័យក្នុងជីវិត យើងចាំបាច់ត្រូវនឹកស្រមៃថា ខ្លួននឹងបានខ្ពង់ខ្ពស់ប៉ុណ្ណា ពេលបានជោគជ័យ និងត្រូវអួតខ្លួន ហើយបង្ហាញសមត្ថភាពឲ្យគេឃើញជាដើម។ តែសេចក្ដីស្រឡាញ់ដ៏ពិត មិនអួតអំពីជោគជ័យរបស់ខ្លួន ឬចង់បង្ហាញឲ្យគេឃើញស្នាដៃរបស់យើងឡើយ។ ព្រះគម្ពីរបានថែងអំពីបញ្ហានេះ តាំងពីសម័យបុរាណមកម្ល៉េះ។ គឺដូចដែលស្ដេចសាឡូម៉ូន បានមានបន្ទូលយ៉ាងច្បាស់ថា "ទុកឲ្យមនុស្សឯទៀតសរសើរឯងចុះ កុំឲ្យមាត់ឯងសរសើរខ្លួនឡើយ គឺជាអ្នកដទៃ មិនមែនជាបបូរមាត់របស់ឯងឡើយ"(សុភាសិត ២៧:២)។ និយាយឲ្យខ្លី សេចក្ដីស្រឡាញ់ដ៏ពិត មិនព្យាយាមបង្អួតខ្លួនឲ្យអ្នកដទៃសរសើរឡើយ។

**អាចកំបាំង ដើម្បីឲ្យយើងមានចិត្តល្អ ពេលមានការខកចិត្ត គឺយើងត្រូវមានទំនុកចិត្តដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះដែលផ្គត់ផ្គង់យើង ដែលព្រះអង្គក៏ជាអ្នកគង្វាល និងឪពុករបស់យើងផងដែរ។**

សេចក្ដីស្រឡាញ់មិនចេះច្រណែនឈ្នានីសទេ។ ការច្រណែនជាការចង់បានរបស់អ្វី ដែលអ្នកដទៃមាន ហើយការអួតខ្លួន ជាការព្យាយាមធ្វើឲ្យអ្នកដទៃច្រណែននឹងអ្វីដែលយើងមាន។ ការច្រណែនជាការបន្ទាបអ្នកដទៃឲ្យអន់ថោក ហើយការអួតខ្លួនលើកដំកើងខ្លួនឯងឲ្យខ្ពស់ឡើង។

ទោះជាយ៉ាងណាក៏ដោយ សេចក្ដីស្រឡាញ់ដ៏ពិត មិនគ្រាន់តែអបអរចំពោះជោគជ័យរបស់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងដឹងថា ត្រូវធ្វើយ៉ាងណា ពេលខ្លួនទទួលជោគជ័យ គឺត្រូវប្រព្រឹត្តដោយចិត្តស្លូតបូត និងបន្ទាបខ្លួន។

## សេចក្ដីស្រឡាញ់ដ៏ពិត "មិនមានចិត្តធំ"

ត្រង់ចំណុចនេះ ក្នុងព្រះគម្ពីរដើមជាភាសាក្រិក សាវ័កប៉ុលបានប្រើពាក្យដែលប្រែមកថា "អួតបំប៉ោងខ្លួន"។ គាត់ក៏បានប្រើពាក្យនេះ ក្នុងការលើកទឹកចិត្តគ្រីស្ទបរិស័ទដែលគ្មានសេចក្ដីស្រឡាញ់ នៅទីក្រុងកូរិនថូស កុំឲ្យពួកគេ "អួតពីអ្នកមួយទាស់នឹងអ្នកមួយ"(១កូរិនថូស ៤:៦)។

ក្នុងបទគម្ពីរមុនៗ សាវ័កប៉ុលបានពិពណ៌នាថា ពួកជំនុំក្រុងកូរិនថូសគិតអំពីខ្លួនឯងខ្លាំងពេក បានជាពួកគេមិនបានខ្វល់ពីទុក្ខលំបាករបស់អ្នកដទៃ។ បន្ទាប់មកក្នុងជំពូក១៣ គាត់បានប្រើពាក្យដដែលឆ្លុះបញ្ចាំង អំពីភាពក្រអើតក្រទម ដែលធ្វើ

ឲ្យយើងមិនព្រមទទួលជំនួយពីអ្នកដទៃ ហើយបញ្ហានេះ ក៏បានបណ្តាលឲ្យយើង មិនងាយឆ្លើយតប ចំពោះអ្នកដែលត្រូវការជំនួយពីយើង។

អ្នកដែលអួតបំប៉ោងខ្លួនឯង គិតអំពីខ្លួនឯងខ្លាំងពេក ដោយយល់ថា ខ្លួនឯងជាមនុស្សសំខាន់ខុសពីការពិត ហើយសន្និដ្ឋានថា សុភមង្គល គំនិត និងអារម្មណ៍របស់ខ្លួន សំខាន់លើសអ្វីៗទាំងអស់។ អ្នកអួតបំប៉ោងខ្លួន ងាយនឹងបដិសេធសេចក្តីត្រូវការ និងអារម្មណ៍របស់អ្នកដទៃ។

សេចក្តីបង្រៀនក្នុងព្រះគម្ពីរសញ្ញាថ្មី អំពីសេចក្តីស្រឡាញ់ដ៏ពិត មិនបានបង្រៀនយើង ឲ្យឈប់គិតអំពីសេចក្តីត្រូវការរបស់យើងឡើយ។ គឺគ្រាន់តែបានបង្រៀនយើងឲ្យចងចាំថា យើងមិនត្រូវគិតពីប្រយោជន៍ផ្ទាល់ខ្លួន ជាសំខាន់ជាងប្រយោជន៍របស់អ្នកដទៃឡើយ។

*យើងអាចឆែកពិនិត្យមើលខ្លួនឯង នៅក្នុងការអធិស្ឋាន ដើម្បីឲ្យដឹងថា ខ្លួនមានការអួតបំប៉ោងខ្លួនឬអត់។ គឺត្រូវសួរខ្លួនឯងថា តើយើងអធិស្ឋានឲ្យតែខ្លួនឯង និងសម្រាប់តែប្រយោជន៍ផ្ទាល់ខ្លួន ឬយើងអធិស្ឋានឲ្យកូនៗ ប្តីប្រពន្ធ និងអ្នកដទៃ ដោយការយកចិត្តទុកដាក់ចំពោះពួកគេឬទេ?*

## សេចក្តីស្រឡាញ់ពិត "មិនប្រព្រឹត្តបែបមិនគួរសម"

ក្នុងព្រះគម្ពីរសញ្ញាថ្មី ក្រៅពីបទគម្ពីរ ១កូរិនថូស ជំពូក ១៣ មានបទគម្ពីរមួយទៀត ដែលនិយាយអំពីសេចក្តីស្រឡាញ់ ដែលមិនប្រព្រឹត្តបែបមិនគួរសម ឬមិនគួរគប្បី (១កូរិនថូស ៧:៣៦) ដែលបទគម្ពីរនេះ បានពិពណ៌នា អំពីទំនាក់ទំនងរវាងគូស្នេហ៍ដែលមិនទាន់រៀបការ។ ពាក្យប្រព្រឹត្តបែបមិនគួរសម អាចប្រែមកថា "ប្រព្រឹត្តខុសសីលធម៌ មិនសមរម្យ ឬខុសរបៀប"។ សាវ័កប៉ុលបានបង្រៀន ដោយនិយាយសង្កត់ធ្ងន់ថា យើងត្រូវស្រឡាញ់ព្រះជាទីមួយ តែទន្ទឹមនឹងនោះ សម្រាប់បុរសនិងស្ត្រីដែលជាគូស្នេហ៍ ដែលកំពុងជួបការល្បួងខាងផ្លូវភេទ ពួកគេត្រូវរៀបការ ជាជាង "ប្រព្រឹត្តខុសសីលធម៌"។

តើ "ការប្រព្រឹត្តបែបមិនគួរសម" មានទំនាក់ទំនងអ្វី នឹងគោលការណ៍នៃសេចក្តីស្រឡាញ់ដ៏ពិត ដែលបានចែងក្នុង១កូរិនថូស ១៣? តាមពិត សេចក្តីបង្រៀន

នោះបានរំឭកយើងថា លក្ខណៈដ៏ត្រឹមត្រូវនៃសេចក្តីស្រឡាញ់ គឺមិនធ្វើការទាមទាអ្នកដទៃ ឲ្យធ្វើអ្វីដែលខុសសីលធម៌ឡើយ។ ក្តីស្រឡាញ់ដ៏ពិត មិនដែលជម្រុញគូស្នេហ៍របស់ខ្លួន ដោយនិយាយថា "សូមអូនលះបង់ខ្លួនប្រាណឲ្យបង ដើម្បីបញ្ជាក់ថា អូនពិតជាស្រឡាញ់បងមែន"។ ម្យ៉ាងទៀត អ្នកដែលមានក្តីស្រឡាញ់ មិនដែលប្រាប់អ្នកដែលខ្លួនស្រឡាញ់ ឲ្យបង្ហាញភាពស្មោះត្រង់ចំពោះខ្លួន ដោយនិយាយកុហក់ បោកប្រាស់ ឬលួចរបស់ទ្រព្យរបស់អ្នកដទៃឡើយ។

សេចក្តីស្រឡាញ់ដ៏ពិតមិនដែលប្រើមិត្តភាព ដើម្បីដាក់សំពាធមកលើអ្នកដទៃឲ្យធ្វើអ្វីមួយ ដែលប្រាសចាកនឹងគោលការណ៍នៃសម្បជញ្ញៈ ឬសេចក្តីជំនឿ ឬខុសនឹងគោលការណ៍នៃក្រមសីលធម៌របស់ព្រះឡើយ។ គេបានប្រើសេចក្តីស្រឡាញ់ជាលេស ដើម្បីបង្ខំឲ្យប្រព្រឹត្តអំពីអសីលធម៌ផ្លូវភេទដ៏អាក្រក់បំផុត ហើយលាក់បាំងអំពើស្មោកគ្រោក និងអាថ៌កំបាំងដែលអសីលធម៌បំផុត នៅក្នុងគ្រួសារ ក្រុមជើងកាង ក្រុមមនុស្ស ឬទំនាក់ទំនង។ តែសេចក្តីស្រឡាញ់មិនមែនជាឧបករណ៍សម្រាប់បង្ខំគេឲ្យប្រព្រឹត្តការអាក្រក់ឡើយ។

## សេចក្តីស្រឡាញ់ដ៏ពិត "មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន"

តាមធម្មតា សាវ័កប៉ុលចូលចិត្តប្រើពាក្យពេចន៍ដូចនេះ ដើម្បីពិពណ៌នា អំពីការមិនគិតប្រយោជន៍ផ្ទាល់ខ្លួន។ គឺនិយាយអំពីអ្នកដែលផ្តោតទៅលើប្រយោជន៍អ្នកដទៃ។ ក្នុងបទគម្ពីរភីលីព ជំពូក២ សាវ័កប៉ុលបានបង្ហាញគោលការណ៍នៃសេចក្តីស្រឡាញ់ដ៏ពិត យ៉ាងដូចនេះថា "កុំឲ្យធ្វើអ្វី ដោយទាស់ទែងគ្នា ឬដោយសេចក្តីអំនួតឥតប្រយោជន៍ឡើយ តែចូររាប់អានគេឲ្យលើសជាងខ្លួន ដោយចិត្តសុភាពវិញ កុំឲ្យគ្រប់គ្នាស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ ត្រូវស្វែងរកចំពោះអ្នកដទៃផង"( ខ.៣-៤ )។

គោលបំណងដ៏ធំរបស់សាវ័កប៉ុល គឺចង់ឲ្យអ្នកដែលបានទទួលព្រះនាមព្រះយេស៊ូវ មានការរួបរួមគ្នា មានចិត្តគំនិតតែមួយ។ តែការរួបរួមនេះ មិនអាចកើតមាននៅក្នុងពួកជំនុំ ទំនាក់ទំនងប្តីប្រពន្ធ ឬទំនាក់ទំនងផ្សេងទៀតបានឡើយ បើសិនជាយើងមិនបានគិតពីប្រយោជន៍អ្នកដទៃឲ្យបានខ្លាំង ដូចដែលយើងបានគិតពីប្រយោជន៍ខ្លួនឯងទេនោះ។ សាវ័កប៉ុលថែមទាំងបាននិយាយទៀតថា សេចក្តីស្រឡាញ់ដ៏ពិត ចាត់ទុកសេចក្តីត្រូវការរបស់អ្នកដទៃ ជាសំខាន់ជាងសេចក្តីត្រូវការ

របស់ខ្លួនឯង។ ការលះបង់ខ្លួនឯងយ៉ាងដូចនេះ គឺខុសពីនិស្ស័យសាច់ឈាមរបស់មនុស្ស តែបានឆ្លុះបញ្ចាំងពីបំណងព្រះទ័យរបស់ព្រះគ្រីស្ទ(ភីលីព ២:៥)។ ព្រះអង្គបានបន្ទាបខ្លួន ដោយយាងចេញពីព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ដើម្បីមកចាប់កំណើតជាមនុស្ស ដែលមានសាច់ឈាម ដែលអំណាចមានកំណត់ ដើម្បីដើរនៅលើលោកិយនេះ ក្នុងភាពក្រីក្រ ដើម្បីធ្វើជាអ្នកបម្រើដល់មនុស្ស ដែលបដិសេធព្រះអង្គ ដើម្បីលាងជើងពួកសាវ័ក ដែលរត់ចោលព្រះអង្គ ដើម្បីសុគតនៅលើឈើឆ្កាង ដើម្បីលោះបាបមនុស្ស ដែលមិនសក្តិសមនឹងព្រះអង្គ។ ការរស់នៅរបស់ព្រះយេស៊ូវ បានធ្វើជាគំរូនៃការយកអ្នកដទៃជាសំខាន់ជាងខ្លួនឯង។

## សេចក្តីស្រឡាញ់ដ៏ពិត "មិនរហ័សខឹង"

ក្នុងការបកស្រាយអំពីអត្ថន័យនៃសេចក្តីស្រឡាញ់ដ៏ពិត សាវ័កប៉ុលបានប្រើពាក្យ "មិនរហ័សខឹង" ដែលពិពណ៌នាអំពីចិត្តដែលមិនងាយខឹង។ គឺអាចនិយាយបានម្យ៉ាងទៀតថា សេចក្តីស្រឡាញ់ដ៏ពិត មិនឆេវឆាវ ឬមិនឆាប់មានប្រតិកម្ម។ ដូចនេះសេចក្តីស្រឡាញ់មានការអត់ធ្មត់បានយូរ ហើយក៏មិនរហ័សខឹងផង។



យើងងាយនឹងភ្លេចលក្ខណៈដ៏សំខាន់មួយនេះ នៃសេចក្តីស្រឡាញ់ដ៏ពិត។ ប្តីប្រពន្ធដែលរស់នៅជាមួយគ្នាដោយការខកចិត្តចំពោះគ្នាអស់ជាច្រើនឆ្នាំ ក៏បានប្រែក្លាយជារហ័សខឹងនឹងគ្នា។ ឪពុកម្តាយដែលស្រឡាញ់កូន បែរជានិយាយគំហក ដោយពាក្យសម្តីអាក្រក់ៗ ពេលមានចិត្តតប់ប្រម៉ល់ខ្លាំង។ បុគ្គលិកបង្ហាញភាពឆេវឆាវ ពេលដែលប្រធាន ឬមិត្តរួមការងាររបស់ខ្លួន មិនបានផ្តល់នូវការយកចិត្តទុកដាក់ ជាមូលដ្ឋាន។

ហេតុអ្វីបានជាយើងរហ័សខឹង? ជួនកាល យើងមានចិត្តក្តៅក្រហាយ ដោយសារយើងចង់បានអ្វីមួយ តែមិនបានសម្រេចដូចបំណង។ ជួនកាល កំហឹងរបស់យើង ជាភស្តុតាងនៃភាពអាត្មានិយមរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ មិនមែនកំហឹងទាំងអស់សុទ្ធតែបណ្តាលមកពីភាពអាត្មានិយមឡើយ។

ក្នុងបទគម្ពីរកិច្ចការ ១៧:១៦ យើងឃើញថា "កំពុងដែលប៉ុលចាំគេនៅក្រុងអាថែន នោះគាត់មានសេចក្តីរំជួលក្នុងចិត្តជាខ្លាំង ដោយឃើញមានរូបព្រះនៅពេញក្នុងទីក្រុងនោះ"។ ត្រង់ចំណុចនេះ សាវ័កប៉ុលពិតជាមានចិត្តខឹងនឹងគេភ្លាមៗ តែ

ដោយសេចក្ដីស្រឡាញ់ទេ។ ពេលដែលគាត់បានឃើញ និងគិតអំពីការថ្វាយបង្គំរូបព្រះរបស់មនុស្សនៅទីក្រុងនោះ គាត់មានចិត្តកាន់តែខ្វល់ខ្វាយ និងមិនសប្បាយចិត្តជួសអ្នកដែលកំពុងវេងគ្រោះ និងវង្វេងដោយសារសាសនាក្លែងក្លាយនោះ។

ព្រះយេស៊ូវក៏មានព្រះពិរោធផងដែរ ពេលដែលព្រះអង្គផ្កាប់តុរបស់ពួកអ្នកដូរប្រាក់ នៅព្រះវិហារ។ ព្រះអង្គបានធ្វើដោយសេចក្ដីស្រឡាញ់ ល្មមនឹងព្រះពិរោធចំពោះការដែលគេនាំគ្នារកស៊ីជួញដូរ នៅដំណាក់នៃព្រះវរបិតារបស់ព្រះអង្គ ដែលជាទីសម្រាប់អធិស្ឋាន។ ពេលនោះ ព្រះអង្គគិតដល់អ្នកដែលបាត់បង់កន្លែងស្ងប់ស្ងាត់ សម្រាប់អធិស្ឋាន(ម៉ាថាយ ២១:១២-១៣)។

ត្រង់ចំណុចនេះ ព្រះយេស៊ូវមិនបានបង្ហាញព្រះទ័យឆេវឆាវ ដែលជាសញ្ញាបញ្ជាក់អំពីការខ្វះសេចក្ដីស្រឡាញ់នោះឡើយ។ ពេលដែលកាលៈទេសៈពេលនោះធ្វើឲ្យព្រះអង្គព្រះពិរោធ ព្រះអង្គក៏បានប្រឆាំងនឹងការប្រព្រឹត្តខុស ដែលកំពុងតែនាំឲ្យមានផលអាក្រក់មកលើអ្នកដែលព្រះអង្គស្រឡាញ់។

ដូចនេះ បទពិសោធន៍របស់សាវ័កប៉ុល នៅក្រុងអាថែន និងសកម្មភាពរបស់ព្រះយេស៊ូវក្នុងព្រះវិហារ បានរំឭកយើងថា មានពេលខ្លះ យើងក៏ត្រូវខឹងផងដែរ។ តែការខឹងនោះ ត្រូវតែបង្ហាញចេញមក ដោយក្ដីស្រឡាញ់ មិនមែនដោយអំពើបាបទេ(អេភេសូរ ៤:២៦)។

## សេចក្ដីស្រឡាញ់ដ៏ពិត "មិនប្រកាន់ទោស"

ក្នុងព្រះគម្ពីរដើមជាភាសាក្រិក ពាក្យ "មិនប្រកាន់ទោស" ជាពាក្យបច្ចេកទេស ដែលគេប្រើក្នុងផ្នែកគណនេយ្យ ដែលប្រែមកថា "បូកសរុប ឬកត់ចូលក្នុងបញ្ជី ឬសៀវភៅ នូវការអាក្រក់ដែលគេបានធ្វើមកលើខ្លួន"។ បានសេចក្ដីថា សេចក្ដីស្រឡាញ់ដែល "មិនប្រកាន់ទោស" មិនកត់ទុកនូវការអាក្រក់របស់អ្នកដទៃ ដើម្បីសងសឹកនៅពេលក្រោយនោះទេ។ សេចក្ដីស្រឡាញ់ដ៏ពិត មិនមានចិត្តគំគួន ឬមានចិត្តខឹងអស់ពេលយូរ ចំពោះអ្នកដទៃ។ ពេលយើងកត់ទុកនូវកំហុសរបស់អ្នកដទៃ ដោយមានចេតនាចង់ឲ្យគាត់ទទួលរងការអាក្រក់នោះវិញ នោះយើងអាចធ្លាក់ខ្លួនជាប់ជំពាក់លើសពីលទ្ធភាពដែលយើងអាចដោះខ្លួនឲ្យរួចទៅទៀត។ "ការវាយបក" ទៅរកគូ

ប្រកួតវិញ ជាទង្វើដ៏ប្រសើរនៅក្នុងការប្រកួតកីឡា តែក្នុងកិច្ចការនៃក្តីស្រឡាញ់ យើងមិនអាចធ្វើដូចនេះបានទេ។ មនុស្សយើងចូលចិត្តកត់ទុកនូវកំហុសដែលគេធ្វើមកលើយើង ដើម្បីការពារខ្លួនកុំឲ្យគេធ្វើខុសមកលើខ្លួនទៀត។ តែសេចក្តីស្រឡាញ់ដ៏ពិត មិនកត់ទុកនូវកំហុសរបស់អ្នកដទៃទេ ព្រោះសេចក្តីស្រឡាញ់ដ៏ពិត មានការជឿជាក់លើការការពារ នៅក្នុងព្រះវត្តមាន និងការផ្គត់ផ្គង់របស់ព្រះ។ យើងដឹងថា ព្រះទ្រង់គ្រប់គ្រងលទ្ធផលរបស់បញ្ហានីមួយៗហើយ ដូចនេះ យើងមិនចាំបាច់ត្រូវកត់ទុកនូវកំហុសរបស់អ្នកដទៃទេ។ ម្យ៉ាងទៀត ព្រះអង្គកំពុងតែយកព្រះទ័យទុកដាក់ចំពោះតម្រូវការរបស់យើង។



**សេចក្តីស្រឡាញ់ដ៏ពិត "មិនដែលអរសប្បាយចំពោះសេចក្តីទុច្ចរិតឡើយ"**

ត្រង់ចំណុចនេះ សេចក្តីស្រឡាញ់មិនអរសប្បាយចំពោះការអ្វី ដែលព្រះហាមមិនឲ្យធ្វើនោះឡើយ។ ម្យ៉ាងទៀត សេចក្តីស្រឡាញ់ក៏មិនលាក់ទុកនូវការពេញចិត្ត ចំពោះអំពើអសីលធម៌របស់អ្នកដទៃដែរ។ សេចក្តីស្រឡាញ់ក៏មិនយករឿងអាក្រក់របស់នរណាម្នាក់ ទៅនិយាយប្រាប់អ្នកដទៃ។ សេចក្តីស្រឡាញ់មិននិយាយដើមគេ ដើម្បីឲ្យអ្នកដទៃគិតថា ខ្លួនជាអ្នកចេះដឹង ឬដើម្បីឲ្យមានអារម្មណ៍ថា ខ្លួនគ្រាន់បើជាងមុន ដោយយករឿងដ៏ខ្មាស់អៀនរបស់អ្នកដទៃ ទៅនិយាយប្រាប់គេនោះទេ។

ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីស្រឡាញ់ ពិតជាខ្វល់អំពីផលវិបាករយៈពេលវែងនៃអំពើបាបរបស់អ្នកដទៃ។ ពេលដែលសេចក្តីស្រឡាញ់ជម្រុញយើង ឲ្យបើកបង្ហាញអំពើបាប គឺត្រូវបើកបង្ហាញ ដើម្បីជាប្រយោជន៍អ្នកដទៃ តែបើយើងបើកបង្ហាញ ដោយហេតុផលអ្វីផ្សេង នោះមានន័យថា យើងមិនបានទទួលការជម្រុញចិត្តពីសេចក្តីស្រឡាញ់ទេ។

សេចក្តីស្រឡាញ់ដ៏ពិតដឹងថា សេចក្តីអាក្រក់ដែលមានក្នុងការសប្បាយតែមួយភ្លែត ដោយគ្មានការពិចារណា នឹងបណ្តាលឲ្យគេទទួលផលអាក្រក់ ដែលនាំឲ្យខកចិត្ត។ សេចក្តីស្រឡាញ់ដឹងថា អំពើបាបដែលបានដុះឡើង ចេញពីគ្រាប់ពូជនៃភាព

គោលលទ្ធិដែលល្អ នាំឲ្យយើងមានការគិតដ៏ត្រឹមត្រូវ អំពីព្រះ អំពីខ្លួនឯង និងអ្នកដទៃ។ ការគិតបានត្រឹមត្រូវ ជួយឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក យ៉ាងពិតប្រាកដ និងមានភាពជ្រាលជ្រៅផង។

លូង់ខ្លៅ នឹងលូតឡើង ហើយបង្កើតផលផ្លែដ៏ល្វីងជូរចត់ នៃការបែកបាក់ ការដាច់ចេញពីគេ និងភាពឯកកោ។

សេចក្ដីស្រឡាញ់ដ៏ពិតមិនអាចអរសប្បាយនឹងអំពើបាប ព្រោះសេចក្ដីស្រឡាញ់មិនគិតតែអំពីការសប្បាយនៅថ្ងៃនេះទេ តែក៏គិតអំពីផលវិបាកនៅថ្ងៃស្អែកផងដែរ។ សេចក្ដីស្រឡាញ់មិនអាចចាត់ទុកការអាក្រក់ជាជម្រើស ដោយមិនគិតពីផលវិបាកនោះឡើយ។

## សេចក្ដីស្រឡាញ់ដ៏ពិត "អរសប្បាយនឹងសេចក្ដីពិត"

សាវ័កប៉ុលបានមានប្រសាសន៍ថា សេចក្ដីស្រឡាញ់មិនអរសប្បាយនឹងការអាក្រក់ទេ ហើយគាត់ក៏បានមានប្រសាសន៍ទៀតថា សេចក្ដីស្រឡាញ់ពិតជាអរសប្បាយនឹងសេចក្ដីពិត។ ហេតុអ្វីបានជាគាត់ប្រើពាក្យ "សេចក្ដីពិត"? ហេតុអ្វីបានជាគាត់មិនប្រើពាក្យថា "អរសប្បាយនឹងសេចក្ដីសុចរិត"វិញ?

មូលហេតុដែលសាវ័កប៉ុលបានជ្រើសរើសពាក្យនេះ គឺប្រហែលមានពីសេចក្ដីសុចរិត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងសេចក្ដីពិត។ ក្នុងសំបុត្រទី២ ដែលសាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំ នៅក្រុងថែស្សាឡូនិច គាត់បានមានប្រសាសន៍ អំពីអ្នកដែលនឹងទទួលការជំនុំជម្រះ ដោយសារពួកគេ "ដែលមិនជឿតាមសេចក្ដីពិត គឺពេញចិត្តនឹងសេចក្ដីទុច្ចរិតវិញ"(២ថែស្សាឡូនិច ២:១២)។

ត្រង់ចំណុចនេះ យើងអាចដឹងពីមូលហេតុ ដែលគាត់មានប្រសាសន៍ថា "សេចក្ដីស្រឡាញ់អរសប្បាយនឹងសេចក្ដីពិត"។ គឺគាត់ចង់ឲ្យយើងគិតអំពីទំនាក់ទំនងដ៏សំខាន់ រវាងការអ្វីដែលយើង*ជឿ* និងការអ្វីដែលយើង*ធ្វើ* ។ ម្យ៉ាងវិញទៀត ការអ្វីដែលយើងជឿ ជាកត្តាកំណត់ឲ្យការអ្វីដែលយើងធ្វើ។ ហើយការអ្វីដែលយើងចង់ធ្វើ ជាកត្តាកំណត់ឲ្យការអ្វី ដែលយើងចង់ជឿ។

*ជាទូទៅ ព្រះគម្ពីរបានសន្និដ្ឋានថា សកម្មភាពរបស់មនុស្សកើតចេញពីជំនឿរបស់ខ្លួន។ អ្នកដែលទទួលការចាក់ចុចចិត្ត និងជឿជាក់យ៉ាងច្បាស់ថា ការនិយាយសេចក្ដីពិត ជាជម្រើសដ៏ល្អជាងការនិយាយកុហក គឺច្រើនតែងាយនឹងនិយាយសេចក្ដីពិត ច្រើនជាងអ្នកដែលមិនជឿថា សេចក្ដីពិតមានភាពជំប្រសើរជាងការនិយាយកុហក់។*

ហេតុនេះហើយ បានជាព្រះគម្ពីរបាននិយាយសង្កត់ធ្ងន់យ៉ាងខ្លាំង ទៅលើជំនឿដែលត្រឹមត្រូវ។ គោលលទ្ធិដែលល្អ នាំឲ្យយើងមានការគិតដ៏ត្រឹមត្រូវ អំពីព្រះ អំពីខ្លួនឯង និងអំពីអ្នកដទៃ។ ការគិតបានត្រឹមត្រូវ ជួយឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក យ៉ាងពិតប្រាកដ និងមានភាពជ្រាលជ្រៅផង។

សេចក្ដីទុច្ចរិតបដិសេធសេចក្ដីពិត។ អាកប្បកិរិយាមិនត្រឹមត្រូវ មានឫសគុលក្នុងជំនឿខុសឆ្គង អំពីសេចក្ដីពិត។ ភាពអសីលធម៌ មានឫសគុលនៅក្នុងការកុហក់ខ្លួនឯងថា "ខ្ញុំចេះជាងព្រះ ព្រោះខ្ញុំដឹងថា ត្រូវរកប្រយោជន៍ផ្ទាល់ខ្លួន និងរកប្រយោជន៍ឲ្យអ្នកដទៃយ៉ាងដូចម្ដេច"។

សាវ័កប៉ុលមានហេតុផលដ៏ត្រឹមត្រូវ ពេលគាត់មានប្រសាសន៍ថា សេចក្ដីស្រឡាញ់ "មិនអរសប្បាយនឹងការអាក្រក់ តែអរសប្បាយនឹងសេចក្ដីពិត"។ ដ្បិតការអាក្រក់(សេចក្ដីទុច្ចរិត) មិនគ្រាន់តែជាពាក្យផ្ទុយនឹងសេចក្ដីសុចរិតប៉ុណ្ណោះទេ តែថែមទាំងផ្ទុយនឹងសេចក្ដីពិតផងដែរ។ មានតែការជឿលើសេចក្ដីពិត ដែលចែងអំពីព្រះ អ្នកដទៃ និងអំពីខ្លួនយើងទេ ដែលអាចជួយយើងឲ្យអរសប្បាយនឹងជីវិត តាមរបៀបដ៏ត្រឹមត្រូវបាន។ យើងរៀនស្រឡាញ់គ្នាទៅវិញទៅមក ក្នុងព្រះគុណ និងសេចក្ដីពិត ជាជាងស្រឡាញ់ការស្វែងរកកំហុសគ្នាទៅវិញទៅមក។ ការដោះចេញនូវជំនឿដែលបំផ្លាញខ្លួនយើង អាចជួយឲ្យយើងអរសប្បាយ ពេលដែលយើងរកឃើញភាពក្លាហាន ភាពទៀតត្រង់ ការអត់ធ្មត់ និងភាពស្មោះត្រង់ ក្នុងសេចក្ដីពិត។ នោះហើយជាសេចក្ដីស្រឡាញ់ដ៏ពិត។ សាវ័កប៉ុលបានបកស្រាយ ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃសេចក្ដីសុចរិត និងសេចក្ដីពិតនេះ មុននឹងឈានដល់ការបកស្រាយជាបញ្ចប់អំពី អំពីសេចក្ដីស្រឡាញ់។



## សេចក្តីស្រឡាញ់ "គ្របបាំងទាំងអស់"

ពាក្យ "*គ្របបាំង* " ដែលគេប្រើ ក្នុងព្រះគម្ពីរដើមជាភាសាក្រិក ជាពាក្យដែលមាន មានន័យថា "ដំបូល"។ ដែលពាក្យនេះ បានផ្តល់នូវការបកស្រាយដ៏សាមញ្ញ។ សេចក្តីស្រឡាញ់គ្របបាំង និងការពារ ដូចជាដំបូលផ្ទះ ដែលគ្របពីលើផ្ទះ និងការពារពេលមានព្យុះភ្លៀង។ សេចក្តីស្រឡាញ់នៅតែបន្តធ្វើការល្អ ជាប្រយោជន៍ដល់អ្នកដទៃ ទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

សេចក្តីស្រឡាញ់ទ្រាំទ្រខ្យល់ព្យុះនៃការខកចិត្ត ភ្លៀងនៃបរាជ័យ និងខ្យល់នៃពេលវេលា និងកាលៈទេសៈ។ សេចក្តីស្រឡាញ់គ្របបាំង ពេលមានអាកាសធាតុត្រជាក់ខ្លាំង ក៏ដូចជានៅក្នុងរដូវក្តៅហួតហែង។ សេចក្តីស្រឡាញ់ផ្តល់កន្លែងជ្រក ដែលអាចធន់នឹងស្ថានភាពដ៏អាក្រក់បំផុត។

សេចក្តីស្រឡាញ់មិនការពារអ្នកដទៃ ឲ្យរួចផុតពីទុក្ខលំបាកក្នុងលោកិយដែលមានពេញដោយអំពើបាបទេ។ ហើយក៏មិនការពារអ្នកដទៃ ឲ្យរួចផុតពីផលវិបាកដែលទទួលបានពីការប្រព្រឹត្តរបស់ពួកគេដែរ។ តែសេចក្តីស្រឡាញ់ពិតជាផ្តល់ឲ្យនូវទីកន្លែងដែលមានអ្នកមើលថែរ សម្រាប់អ្នកដែលជួបការបាក់បែក និងឈឺចាប់។

សេចក្តីស្រឡាញ់ទ្រាំទ្រខ្យល់ព្យុះនៃការខកចិត្ត ភ្លៀងនៃបរាជ័យ និងខ្យល់នៃពេលវេលា និងកាលៈទេសៈ។ សេចក្តីស្រឡាញ់គ្របបាំង ពេលមានអាកាសធាតុត្រជាក់ខ្លាំង ក៏ដូចជានៅក្នុងរដូវក្តៅហួតហែង។ សេចក្តីស្រឡាញ់ផ្តល់កន្លែងជ្រក ដែលអាចធន់នឹងស្ថានភាពដ៏អាក្រក់បំផុត។

សេចក្តីស្រឡាញ់ថែមទាំងផ្តល់ឲ្យមនុស្សដែលមិនប្រែចិត្ត នូវអ្នកដែលលើកទឹកចិត្ត និងអធិស្ឋានទូលអង្វរ ឲ្យគាត់ប្រែចិត្តចេញពីអំពើបាប។ សេចក្តីស្រឡាញ់ផ្តល់ឱកាសប្រែចិត្ត ដល់មនុស្សមានបាបដែលធ្ងន់បំផុត។ សេចក្តីស្រឡាញ់ "គ្រប់បាំងទាំងអស់" គឺមិនមែនមានន័យថា សេចក្តីស្រឡាញ់ទទួលយកនូវអំពើបាបរបស់អ្នកដទៃ ដោយឲ្យគេបន្តប្រព្រឹត្តខុសឡើយ។ តែសេចក្តីស្រឡាញ់មិនដែលឈប់យកចិត្តទុកដាក់ និងឈប់ផ្តល់ឱកាសនៃការអត់ឱនទោស។ សេចក្តីស្រឡាញ់មិនដែលឈានទៅដល់ចំណុច ដែលចាប់ផ្តើមមានការស្អប់ខ្ពើម ឬថ្កោលទោសអ្នកដទៃ។

សេចក្តីស្រឡាញ់មានការយកចិត្តទុកដាក់ ល្មមនឹងបន្តអធិស្ឋានឲ្យ អត់ធ្មត់នឹងអំពើបាបរបស់អ្នកដទៃ ប្រឈមមុខដោះស្រាយ ពេលដែលចាំបាច់ និងអត់ទោសឲ្យផង។ តែសេចក្តីស្រឡាញ់ជាដំបូលគ្របបាំង ដែលមានដែនកំណត់។ សេចក្តីស្រឡាញ់ដែលគ្មានលក្ខខ័ណ្ឌយ៉ាងដូចនេះ មិនមែនជាអ្នកការពារដែលទទួលរងអំពើតែម្យ៉ាងទេ តែជាសេចក្តីស្រឡាញ់ដ៏សកម្ម ដែលឆ្លើយតបទៅវិញ ដើម្បីជួយអ្នកប្រព្រឹត្តខុស ដោយមិនដាក់សម្ពាធមកលើការសម្រេចចិត្តរបស់គាត់។ លក្ខណៈនៃសេចក្តីស្រឡាញ់មិនប្រែប្រួល ហើយទន្ទឹមនឹងនោះ សេចក្តីស្រឡាញ់ក៏មានការផ្លាស់ប្តូរយុទ្ធសាស្រ្ត ដែលរកប្រយោជន៍ឲ្យអ្នកដទៃ "ក្នុងគ្រប់ការទាំងអស់"។

## សេចក្តីស្រឡាញ់ "ជឿទាំងអស់"

បើគេមិនបានគិតឲ្យស៊ីជម្រៅទេ គេប្រហែលជាយល់ថា បទគម្ពីរនេះកំពុងបង្រៀនយើងឲ្យធ្វើជាមនុស្សដែលឆាប់ជឿគេ ឬធ្វើជាមនុស្សត្រង់ពេក។ តែនោះមិនមែនជាអ្វីដែលសាវ័កប៉ុលចង់បង្រៀនយើងទេ។ ពេលយើងសិក្សាឲ្យបានស៊ីជម្រៅ ទើបយើងដឹងថា សាវ័កប៉ុលមិនបាននិយាយថា សេចក្តីស្រឡាញ់ *តែងតែ* ជឿគេ ដោយឥតសង្ស័យនោះទេ។ ជួនកាល មិត្តភក្តិដែលមានសេចក្តីស្រឡាញ់ មិនត្រូវប្រញាប់ជឿគ្នាទេ គឺត្រូវពិចារណាឲ្យបានស៊ីជម្រៅ ដើម្បីឲ្យយល់ច្បាស់អំពីចំណុចស្នូលនៃបញ្ហាណាមួយ។

ត្រង់ចំណុចនេះ សាវ័កប៉ុលក៏បានបង្ហាញពីទំនាក់ទំនងជាមូលដ្ឋាន រវាងសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ផងដែរ។ បទគម្ពីរ ១កូរិនថូស ជំពូក១៣ បានរំឭកយើងថា សេចក្តីស្រឡាញ់ដ៏ពិតមានភាពរឹងមាំ ដោយសារជំនឿដែលយើងមាន

> *ព្រះយេស៊ូវបានមានបន្ទូលអំពីភាពចាំបាច់នៃ**ការអត់ធ្មត់** ពេលព្រះអង្គមានបន្ទូលថា "មនុស្សទាំងអស់នឹងស្អប់អ្នករាល់គ្នា ដោយព្រោះឈ្មោះខ្ញុំ ប៉ុន្តែអ្នកណាដែលកាន់ខ្ជាប់ ដរាបដល់ចុងបំផុត អ្នកនោះនឹងបានសង្គ្រោះ"(ម៉ាថាយ ១០:២២)។*

ចំពោះព្រះ។ សេចក្តីស្រឡាញ់ពិតមានការលូតលាស់ និងទ្រទ្រង់ ដោយជំនឿ ពេលដែលយើងជឿលើ "សេចក្តីគ្រប់យ៉ាង" ដែលព្រះបានមានបន្ទូល អំពីព្រះអង្គទ្រង់ អំពីយើងម្នាក់ៗ និងអំពីទំនាក់ទំនងដែលយើងមានជាមួយគ្នា។ បើសិនជាយើង

មានការសង្ស័យ ចំពោះសេចក្តីស្រឡាញ់ ដែលព្រះអង្គមានចំពោះយើង នោះយើងនឹងមិនសូវមានចិត្តចង់ស្រឡាញ់គ្នាទៅវិញទៅមកទៀតទេ។

ព្រះអង្គបានជានាដល់យើងថា ព្រះអង្គមានព្រះទ័យអត់ធ្មត់ និងសប្បុរសចំពោះយើង។ បើយើងមានការសង្ស័យចំពោះការធានានេះ នោះយើងនឹងមិនបង្ហាញការអត់ធ្មត់ និងចិត្តសប្បុរសចំពោះគ្នាឡើយ។ បើយើងមានចិត្តសង្ស័យ ចំពោះការផ្គត់ផ្គង់របស់ព្រះអង្គ នោះយើងនឹងមិនងាយមានចិត្តសប្បុរសចំពោះគេទេ។

កាលណាយើងយល់ច្បាស់អំពីសេចក្តីពិតដែលថែងថា "សេចក្តីស្រឡាញ់ជឿទាំងអស់" នោះយើងក៏ងាយនឹងយល់ច្បាស់អំពីសេចក្តីស្រឡាញ់ ដែលមានលក្ខណៈដូចព្រះយេស៊ូវផងដែរ។ សេចក្តីស្រឡាញ់ដ៏ពិតមានឫសគុល និងមូលដ្ឋានគ្រឹះក្នុងសេចក្តីជំនឿ។ ចំណែកឯសេចក្តីជំនឿវិញ គឺមានឫសគុល និងមូលដ្ឋានគ្រឹះក្នុងការអ្វីដែលព្រះមានបន្ទូល ក្នុងព្រះគម្ពីរ។

បើយើងមិនបន្ត "ជឿលើការទាំងអស់" ដែលព្រះបានមានបន្ទូលទេ នោះសេចក្តីស្រឡាញ់របស់យើង នឹងមិនអាចធន់នៅ ពេលមានការខកចិត្ត ការបដិសេធន៍ និងការជេរស្តីនៃជីវិតឡើយ។ ម្យ៉ាងទៀត បើសិនជាយើងមិនបានសាងសង់សេចក្តីស្រឡាញ់យើងឲ្យបានរឹងមាំ នៅលើព្រះបន្ទូលព្រះទេ នោះសេចក្តីស្រឡាញ់របស់យើងមិនអាចលូតលាស់ទេ។ មានតែដោយសេចក្តីជំនឿលើព្រះប៉ុណ្ណោះ ដែលសេចក្តីស្រឡាញ់អាចបន្តមានភាពរឹងមាំបាន។

## សេចក្តីស្រឡាញ់ "សង្ឃឹមទាំងអស់"

និយមន័យនៃសេចក្តីស្រឡាញ់ត្រង់ចំណុចនេះ គឺមានទំនាក់ទំនងនឹងនិយមន័យមុន។ បើយើងរស់នៅ ដោយជំនឿលើព្រះបន្ទូល និងផែនការរបស់ព្រះ នោះយើងក៏មានហេតុនឹង "សង្ឃឹមទាំងអស់"ផងដែរ។ កាលណាយើងមានជំនឿ ចំពោះព្រះគុណព្រះ នោះគឺមានន័យថា យើងអាចជឿជាក់ថា មនុស្សដែលមានបាប មិនទាន់អស់ផ្លូវទេ។ សេចក្តីស្រឡាញ់អាចមានសង្ឃឹម ដោយសារការអ្វីដែលព្រះអាចធ្វើក្នុងជីវិតមនុស្សម្នាក់ៗ។

យើងមុខជាមិនយល់ទេ បើសិនជាសាវ័កប៉ុលបង្រៀនយើង ឲ្យចេះតែសង្ឃឹមទៅលើអ្វីគ្រប់យ៉ាង ដោយមិនរើសមុខ លើសពីការដែលគាត់បង្រៀនឲ្យជឿ ដោយការយល់ដឹងនោះ។ ប៉ុន្តែ សម្រាប់មនុស្សទាំងអស់ មានតែអ្នកដែលមានជំនឿលើ

ព្រះនៃព្រះគម្ពីរបរិសុទ្ធទេ ដែលមានមូលដ្ឋានគ្រឹះដ៏ល្អ សម្រាប់ឲ្យមានសេចក្តីស្រឡាញ់ និងក្តីសង្ឃឹម ក្នុងលោកិយនេះ។ គឺដូចដែលអ្នកនិពន្ធទំនុកដំកើងបានពោលឡើងថា "ទូលបង្គំសង្ឃឹមដល់ទ្រង់តែ១ប៉ុណ្ណោះ"(ទំនុកដំកើង ៣៩:៧)។ សាវ័កប៉ុលបានសរសេរក្នុងសំបុត្រទៅកាន់ពួកជំនុំ នៅក្រុងរ៉ូមថា "ឯសេចក្តីសង្ឃឹមក៏មិនដែលនាំឲ្យយើងមានសេចក្តីខ្មាសឡើយ"(រ៉ូម ៥:៥)។ ហើយលោកពេត្រុសក៏បានមានប្រសាសន៍ផងដែរថា "សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី ... ដើម្បីឲ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ"(១ពេត្រុស ១:៣)។

នេះជាអំណាចនៃក្តីស្រឡាញ់។ អំណាចនៃសេចក្តីស្រឡាញ់ មិនត្រូវបានជំរុញ និងទ្រទ្រង់ ដោយអារម្មណ៍ដែលចេះតែប្រែប្រួល ឬដោយនិស្ស័យសាច់ឈាមឡើយ តែដោយជំនឿ និងក្តីសង្ឃឹមដ៏ជ្រាលជ្រៅ ដែលព្រះប្រទានដល់អ្នក ដែលទុកចិត្តព្រះអង្គ។ សេចក្តីស្រឡាញ់ដ៏ពិត អាចយល់ពីជីវិត ហើយរស់នៅក្នុងជីវិតនោះ ដោយគំនិតវិជ្ជមានជានិច្ច ដោយសារ "ព្រះគ្រីស្ទ ដែលគង់សណ្ឋិតក្នុងយើង ដែលជាទីសង្ឃឹមយ៉ាងឧត្តម"(កូល៉ុស ១:២៧)។

## សេចក្តីស្រឡាញ់ដ៏ពិត "ទ្រាំទ្រទាំងអស់"

ត្រង់ចំណុចនេះ សាវ័កប៉ុលបានបញ្ចប់ការពិពណ៌នា អំពីអត្ថន័យនៃសេចក្តីស្រឡាញ់ ដែលមានតាំងពីខ.៤មក ដែលផ្តើមដោយពាក្យថា "សេចក្តីស្រឡាញ់តែងតែអត់ធ្មត់"។ យើងអាចដឹងអំពីភាពខុសគ្នា ក្នុងការប្រើពាក្យ "អត់ធ្មត់" និង"ទ្រាំទ្រ" ក្នុងការពិពណ៌នារបស់សាវ័កប៉ុល អំពីសេចក្តីស្រឡាញ់។ ពេលដែលយើងបានដឹងថា អាថ៌កំបាំងដើម្បីឲ្យមានក្តីស្រឡាញ់ដ៏ពិត គឺត្រូវមានជំនឿ និងក្តីសង្ឃឹមដ៏ត្រឹមត្រូវ នោះយើងអាចមានហេតុនឹងនិយាយថា សេចក្តីស្រឡាញ់ "ទ្រាំទ្រទាំងអស់"។

ក្នុងខ.៤ ព្រះគម្ពីរដើមជាភាសាក្រិកប្រើពាក្យ ដែលផ្តោតទៅលើ "ការអត់ធ្មត់យូរអង្វែង" នៅពេលទទួលរងការធ្វើទុក្ខទោស ពីអ្នកដទៃ ដោយគ្មានគំនំ ឬសម្អប់។ ហើយនៅចុងខ.៧វិញ គឺនិយាយសង្កត់ធ្ងន់ ទៅលើរបៀបដែលយើងឆ្លើយតបចំពោះទុក្ខលំបាកក្នុងជីវិតជាទូទៅ។ សេចក្តីស្រឡាញ់មិនចុះចាញ់ មិនឈប់ពាក់កណ្តាលទី ក៏មិនដើរចេញ។ សេចក្តីស្រឡាញ់ទ្រាំទ្រ ពេលមានការឈឺចាប់ ដោយដឹងថា ខ្លួនមានគោលដៅ ដែលសក្តិសមនឹងទ្រាំទ្រ។



*ទី៤*

# សេចក្ដីស្រឡាញ់មិនដែលផុតឡើយ

លោកឡាអិននេល រីគី(Lionel Richie) និងអ្នកស្រីដាយអាណា រ៉ូស(Diana Ross) បានច្រៀងបទចម្រៀងមួយបទ យ៉ាងពិរោះ អំពី "សេចក្ដីស្រឡាញ់ដ៏ស្ថិតស្ថេរ" ដែលគូស្នេហ៍នីមួយៗ ក្នុងវ័យយុវជនសង្ឃឹមថា នឹងទទួលបានក្នុងអាពាហ៍ពិពាហ៍។ សេចក្ដីស្រឡាញ់ដ៏ស្ថិតស្ថេរនេះ មិនអាចកើតមានបានឡើយ បើសិនជាគេមិនអនុវត្តតាមបទគម្ពីរ ១កូរិនថូស ជំពូក១៣ទេនោះ។ គាត់បានបញ្ជាក់អំពីអត្ថន័យនៃសេចក្ដីស្រឡាញ់ ក្នុងជំពូក១៣ កាន់តែច្បាស់ថែមទៀត ដោយមានប្រសាសន៍ថា "សេចក្ដីស្រឡាញ់មិនដែលផុតឡើយ"។ ដោយសារសេចក្ដីស្រឡាញ់ដ៏ពិតមានប្រភព និងជីវិតក្នុងព្រះ នោះសេចក្ដីស្រឡាញ់ដ៏ពិតអាចទ្រាំទ្រទាំងអស់។

សាវ័កប៉ុលបានបញ្ជាក់ច្បាស់ថា អ្វីៗផ្សេងទៀតគ្រាន់តែបណ្ដោះអាសន្ន មិនពេញលេញ និងមិនអាចទុកចិត្តបាន។ តែសេចក្ដីស្រឡាញ់ មិនដូច្នោះឡើយ។ ដោយកម្លាំង និងព្រះគុណព្រះ សេចក្ដីស្រឡាញ់ដ៏ពិតនៅតែអាចបន្តទៅមុខទៀតបាន ទោះជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។ សេចក្ដីស្រឡាញ់ដ៏ពិត នៅតែអាចបន្តទៅមុខទៀត ទោះជាមានការក្បត់ និងការសង្ស័យក៏ដោយ។ សេចក្ដីស្រឡាញ់ដ៏ពិតអាចបន្តទៅមុខទៀត ទោះជាមានការខកចិត្ត និងការធ្វើខុសសីលធម៌។ សេចក្ដីស្រឡាញ់ដ៏ពិតឈ្នះការជេរប្រមាថ និងការច្រណែនរបស់អ្នកដែលចាត់ទុកយើងជាសត្រូវ។ សេចក្ដីស្រឡាញ់ដ៏ពិតនៅតែបន្ត ទោះជាត្រូវគេជំនុំជម្រះឧក្រិដ្ឋកម្ម និងដាក់គុកក៏ដោយ។ សូម្បីតែនៅពេលដែលលក្ខណៈនៃទំនាក់ទំនងយើងមានការប្រែប្រួល ដោយសារការសម្រេចចិត្តខុសក៏ដោយ ក៏សេចក្ដីស្រឡាញ់

របស់ព្រះនៅតែអាចបណ្ដាលចិត្តយើង ឲ្យអធិស្ឋាន ហើយធ្វើការអ្វីម្យ៉ាង ដើម្បីជួយអ្នកដទៃ តាមដែលអាចធ្វើទៅបាន។ សេចក្ដីស្រឡាញ់នេះ ឆ្លុះបញ្ចាំងអំពីព្រះទ័យរបស់ព្រះគ្រីស្ទ និងបើកបង្ហាញអំពីការផ្លាស់ប្ដូរដ៏អស្ចារ្យ ដែលមានតែព្រះអង្គទេ ដែលអាចបង្កើតឲ្យមានសេចក្ដីស្រឡាញ់ដ៏ពិត ក្នុងជីវិតយើងបាន។



*ទី៥*

## តើខ្ញុំអាចទៅរកសេចក្ដីស្រឡាញ់ នៅទីណា?

បើសិនជាដួងចិត្តរបស់អ្នកចង់សួរថា "តើខ្ញុំអាចរកសេចក្ដីស្រឡាញ់ដ៏ពិត ដែលបានរៀបរាប់ក្នុងសៀវភៅនេះ នៅទីណា?" នោះសំណួរនេះគឺងាយស្រួលឆ្លើយទេ។ មានបទគម្ពីរដ៏ពេញនិយមមួយចែងថា "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"(យ៉ូហាន ៣:១៦)។ ត្រង់ចំណុចនេះ ព្រះយេស៊ូវបានពិពណ៌នា អំពីទំហំនៃសេចក្ដីស្រឡាញ់របស់ព្រះ ដល់អ្នកដែលជឿព្រះអង្គ។ គឺដូចដែលព្រះអង្គមានបន្ទូលទៅកាន់ពួកសាវ័កថា "ដូច្នេះ កុំឲ្យខ្វល់ខ្វាយថា តើត្រូវបរិភោគអ្វី ឬស្លៀកពាក់អ្វីនោះឡើយ ដ្បិតគឺជាសាសន៍ដទៃទេតើ ដែលខំស្វែងររបស់ទាំងនោះវិញ ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង"(ម៉ាថាយ ៦:៣១-៣៣)។

យើងចាំបាច់ត្រូវជឿថា ព្រះអង្គពិតជាបានស្រឡាញ់យើងយ៉ាងនេះមែន ទើបយើងអាចមានទំនុកចិត្ត ហ៊ានស្រឡាញ់អ្នកដទៃ ដោយមិនខ្លាចគ្រោះថ្នាក់នៅថ្ងៃក្រោយ។

តើអ្នកបានចាប់ផ្ដើមបោះជំហាន ដើម្បីស្វែងរកសេចក្ដីស្រឡាញ់ ក្នុងអង្គព្រះយេស៊ូវគ្រីស្ទ និងក្នុងការអ្វីដែលព្រះអង្គអាចធ្វើក្នុងជីវិតអ្នកហើយឬនៅ? តើអ្នកទុក

ចិត្តព្រះអង្គទេ? ព្រះគម្ពីរបានចែងថា ព្រះគ្រីស្ទបានសុគតលោះបាបអ្នក តើអ្នកជឿឬទេ?

នោះហើយជាចំណុចដែលត្រូវចាប់ផ្តើម។ សូមទទួលស្គាល់ថា អ្នកជាមនុស្សមានបាប ហើយអ្នកត្រូវការព្រះគ្រីស្ទ ដែលបានយាងមក "ស្វែងរក និងសង្គ្រោះមនុស្សបាត់បង់"(លូកា ១៩:១០)។ យើងអាចស្វែងរកសេចក្តីស្រឡាញ់របស់ព្រះក្នុងអង្គព្រះគ្រីស្ទ ហើយមានតែនៅក្នុងព្រះអង្គទេ ដែលយើងអាចយល់ពីអត្ថន័យនៃការរស់នៅ ដោយសេចក្តីស្រឡាញ់ ដែលសាវ័កប៉ុលបានរៀបរាប់នោះ។

ព្រះអង្គជាព្រះដែលមិនគ្រាន់តែបានត្រាសហៅយើង ឲ្យរស់នៅដោយខ្នាតគំរូដែលខ្ពស់ជាងមុនប៉ុណ្ណោះទេ តែថែមទាំងបានត្រាសហៅយើង ឲ្យរស់នៅដោយទីបន្ទាល់ល្អ ដើម្បីឲ្យអ្នកដទៃឃើញព្រះអង្គរស់ក្នុងជីវិតយើង។

# ក្រុមសៀវភៅការរុករកឃើញ

*ការងារបេសកកម្មរបស់យើងខ្ញុំ គឺដើម្បីឲ្យមនុស្សគ្រប់រូបមានឱកាសទទួល និងមានការយល់ដឹងអំពីប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ។*

ក្រុមសៀវភៅការរុករកឃើញ បកស្រាយអំពីសេចក្តីពិតនៃព្រះយេស៊ូវគ្រីស្ទដល់លោកិយ ដោយប្រើធនធានដែលមានគុណភាព ដែលគួរឲ្យចាប់អារម្មណ៍ និងអាចរកបាន ដែលបង្ហាញថា ព្រះគម្ពីរមានសារៈសំខាន់បំផុតចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិត។ កូនសៀវភៅ នៅក្នុងក្រុមសៀវភៅការរុករកឃើញ គឺអាចរកបាន ដោយឥតគិតថ្លៃ ហើយអាចត្រូវបានប្រើសម្រាប់ការសិក្សាផ្ទាល់ខ្លួន ក្នុងក្រុមតូច ឬក្នុងការងារឃោងចាប់។

យើងខ្ញុំសូមអរគុណ សម្រាប់ការគាំទ្រធនធានរបស់ក្រុមសៀវភៅការរុករកឃើញ និងអង្គការនំម៉ាណាប្រចាំថ្ងៃ។ មានគ្រីស្ទបរិស័ទជាច្រើនបានរួមចំណែកក្នុងការដាក់ដង្វាយឧបត្ថម្ភ ទោះតិចតួច ឬច្រើនក្តី ដល់អង្គការនំម៉ាណាប្រចាំថ្ងៃ ដើម្បីឲ្យឃោងចាប់អ្នកដទៃ ដោយប្រាជ្ញានៃព្រះគម្ពីរដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ យើងខ្ញុំមិនបានទទួលប្រាក់ជំនួយពីក្រុម ឬនិកាយណាមួយឡើយ។